ក N°56/15 31/7/2015

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ២~ព្រះរាជក្រឹត្យ


០១-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៦៩៤ ស្តីពី ការប្រគល់ភារកិច្ចជូនឯកឧត្តម **អ៊ុក សោភ័ណ** ឱ្យបំពេញមុខងារ ជាអគ្គនាយក នៃអគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ៦០៤៧

០១-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៦៩៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ អស់លោក ចំនួន ០២ រូប ៦០៤៨

០១-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៦៩៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះលោកសាស្ត្រាចារ្យ Pascal MILLET ៦០៤៩

០១-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៦៩៧ ស្តីពី ការតែងតាំងឯកឧត្តម **ម៉ៅ សុវណ្ណារ៉េត** ជានាយកខុទ្ទកាល័យ អនុប្រធានទី ២ ព្រឹទ្ធសភា នីតិកាលទី ៣ ឋានៈ អគ្គនាយក ៦០៥០

០១-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៦៩៨ ស្តីពី ការបង្កើតគណៈកម្មការដើម្បីពិនិត្យលក្ខណ វិនិច្ឆ័យសម្រាប់ការធ្វើសមាហរណកម្មទៅក្នុងថ្នាក់ និងឋានន្តរស័ក្តិនៃចៅក្រម និងព្រះរាជអាជ្ញា ៦០៥១

០២-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៦៩៩ ស្តីពី ការតែងតាំង និងតម្លើងឋានៈជាអគ្គនាយក អគ្គលេខាធិការ អគ្គលេខាធិការរង អគ្គាធិការ ទីប្រឹក្សាអមក្រសួង និងជំនួយការអមក្រសួង បរិស្ថាន ចំនួន ១៥ រូប ៦០៥៣

០២-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧០០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ៤៦ រូប ៦០៥៥

០២-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧០១ ស្តីពី ការតែងតាំងលោកជំទាវ **ម៉ុំ ថាវី ស៊ិន សុខណា** ជា ឧកញ៉ា ៦០៥៧

០២-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧០២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ លោកជំទាវ **ម៉ុំ ថាវី ស៊ិន សុខណា** ៦០៥៨

០២-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧០៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយ យស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងកញ្ញា ចំនួន ២១ រូប ៦០៥៩

០២-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧០៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ និងអស់លោក ចំនួន ២៥ រូប ៦០៦០

# II-រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

២៣-៧-២០១៥ -អនុក្រឹត្យលេខ ៩៥ អនក្រ.បក ស្តីពី ការដំឡើងវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៦០៦២

២៤-៧-២០១៥ -អនុក្រឹត្យលេខ ៩៦ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៦០៦៧

២៤-៧-២០១៥ -អនុក្រឹត្យលេខ ៩៧ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៦០៦៩

២៤-៧-២០១៥ -អនុក្រឹត្យលេខ ៩៨ អនក្រ.បក ស្តីពី ការគ្រប់គ្រងអាងទន្លេ ៦០៧១

១០-៧-២០១៥ -អនុក្រឹត្យលេខ ៧៤២ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦០៨៤

១០-៧-២០១៥ -អនុក្រឹត្យលេខ ៧៤៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦០៨៦

១០-៧-២០១៥ -អនុក្រឹត្យលេខ ៧៤៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦០៨៨

១០-៧-២០១៥ -អនុក្រឹត្យលេខ ៧៤៥ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ ៦០៨៩

១០-៧-២០១៥ -អនុក្រឹត្យលេខ ៧៤៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦០៩០

១០-៧-២០១៥ -អនុក្រឹត្យលេខ ៧៤៧អនក្រ.តត ស្តីពី ការតែងតាំងសមាជិកថេរសភានៃព្រះពុទ្ធសាសនានៅព្រះរាជាណាចក្រកម្ពុជា ៦០៩២

១០-៧-២០១៥ -អនុក្រឹត្យលេខ ៧៤៨ អនក្រ.តត ស្តីពី ការបំពេញក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ៦០៩៣

១០-៧-២០១៥ -អនុក្រឹត្យលេខ ៧៤៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦០៩៤

១០-៧-២០១៥ -អនុក្រឹត្យលេខ ៧៥០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦០៩៥

១៣-៧-២០១៥ -អនុក្រឹត្យលេខ ៧៥១ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៦០៩៦

១៣-៧-២០១៥ -អនុក្រឹត្យលេខ ៧៥២ អនក្រ.តត ស្តីពី ការលុបឈ្មោះនាយទាហាន ៦០៩៨

១៣-៧-២០១៥ -អនុក្រឹត្យលេខ ៧៥៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦០៩៩

១៣-៧-២០១៥ -អនុក្រឹត្យលេខ ៧៥៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦១០០

១៣-៧-២០១៥ -អនុក្រឹត្យលេខ ៧៥៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦១០១

១៣-៧-២០១៥ -អនុក្រឹត្យលេខ ៧៥៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦១០២

១៣-៧-២០១៥ -អនុក្រឹត្យលេខ ៧៥៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦១០៥

១៣-៧-២០១៥ -អនុក្រឹត្យលេខ ៧៥៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦១០៦

## ២-សេចក្តីសម្រេច

២០-៧-២០១៥ -សេចក្តីសម្រេចលេខ ៥៨ សសរ ស្តីពី ការកែសម្រួលសមាជិកក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៦១០៧

២២-៧-២០១៥ -សេចក្តីសម្រេចលេខ ៥៩ សសរ ស្តីពី ការបង្កើតក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ៦១០៩

## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៦-៧-២០១៥ -ប្រកាសអន្តរក្រសួងលេខ ៧០៧ សហវ.ប្រក ស្តីពី ការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន របស់ក្រសួងអប់រំ យុវជន និងកីឡា នៅនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ៦១១៤

០៨-៧-២០១៥ -ប្រកាសលេខ ៧២១ សហវ.ប្រក ស្តីពី ការបង្កើត និងតែងតាំងក្រុមលទ្ធកម្មរបស់គណៈកម្មការមូលបត្រកម្ពុជា ៦១១៦

១៦-៧-២០១៥ -ប្រកាសលេខ ៨២៩ សហវ.ប្រក ស្តីពី ការកែសម្រួលប្រការ ៤ ប្រការ ៥ ប្រការ ១៤ ប្រការ ១៦ និងប្រការ ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៤ ស្តីពី នីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ៦១១៩

### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

៣០-៤-២០១៥ -ប្រកាសបង្កើតរោងចក្រលេខ ១៩៤ ឧស.កឧ.ប្រក.០៤ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន តៃអ៊ីហ្វី អ៊ិនធើណេសិនណល បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៦១២៣

០៥-៥-២០១៥ -ប្រកាសបង្កើតរោងចក្រលេខ ១៩៧ ឧស.កឧ.ប្រក.០៥ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជុងហ្វៃ នីតវៀរ អេហ្វធីវ៉ាយ បង្កើតសាខារោងចក្រ ផលិតអាវចាក់ ៦១២៦

### ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៩-០១-២០១៥ -លិខិតបញ្ជាក់លេខ ០៤៦២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **តីតី អ៊ុលីត ឡៃលធី លីមីធីត** ៦១២៩

១៩-០១-២០១៥ -លិខិតបញ្ជាក់លេខ ០៤៦៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អ៊ីអាន ថេក (ខេមបូឌា)** ៦១៣១

១៩-០១-២០១៥ -លិខិតបញ្ជាក់លេខ ០៤៦៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **បេនលី អ៊ិនវេសម៉ិន (ខេមបូឌា)** ៦១៣៣

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៦៩៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ប្រគល់ភារកិច្ចជូនឯកឧត្តម **អ៊ឹក សោភ័ណ** ឱ្យបំពេញមុខងារ ជា**អគ្គនាយក** នៃអគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤៧.១៥០៧.៧០០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៥*

លេខ:៧១១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៦៩៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

**ក-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា**

-លោកសាស្ត្រាចារ្យ NAM HAM CHO

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

-លោកសាស្ត្រាចារ្យរង **សេក សុខឃឿន**

៣៧៧.១៥០៧.៧០១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៥*

លេខ: ៧០៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៦៧៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

**-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា**

-លោកសាស្ត្រាចារ្យ Pascal MILLET

៣៣៧.១៥០៧.៣០៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៥*

លេខ: ៧០៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៦៣៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់ឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រា ទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភា បានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់លទ្ធផល នៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំវិសាមញ្ញ នីតិកាលទី ៣ នៃព្រឹទ្ធសភា នាថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១៥ ស្តីពីការជ្រើសតាំងប្រធាន និងអនុប្រធានទី១ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង **ឯកឧត្តម ប៊ូ សុវណ្ណារ៉េត** ជានាយកខុទ្ទកាល័យ អនុប្រធានទី២ ព្រឹទ្ធសភា នីតិកាលទី៣ ឋានៈ **អគ្គនាយក** ។

**មាត្រា២ :** ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៨ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៥ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣ :** **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

១៧.១៥០៧.៧០៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥*

លេខៈ ៧១៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

**នស/រកត/០៧១៥/ ៦៩៨**

## ស្តីពី

## ការបង្កើតគណៈកម្មការដើម្បីពិនិត្យលក្ខណវិនិច្ឆ័យសម្រាប់ការធ្វើសមាហរណកម្មទៅក្នុងថ្នាក់ និងឋានន្តរស័ក្តិនៃចៅក្រម និងព្រះរាជអាជ្ញា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៣៩៨ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីឋានន្តរស័ក្តិ និងថ្នាក់សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

## ត្រាស់បង្គាប់

**មាត្រា ១**: ត្រូវបានបង្កើតគណៈកម្មការដើម្បីពិនិត្យលក្ខណវិនិច្ឆ័យសម្រាប់ការធ្វើសមាហរណកម្មទៅក្នុងថ្នាក់ និងឋានន្តរស័ក្តិនៃចៅក្រម និងព្រះរាជអាជ្ញា ស្របតាមមាត្រា ១០៨ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលមានសមាសភាព៖

១-ឯកឧត្តម **អង្គ វង្សវឌ្ឍានា**    រដ្ឋមន្ត្រីក្រសួងយុត្តិធម៌    ប្រធាន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

| | | |
|---|---|---|
| ២-ឯកឧត្តម ហ៊ី សោភា | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣-លោកជំទាវ ចាន់ សុទ្ធាវី | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៤-ឯកឧត្តម កើត រិទ្ធ | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៥-ឯកឧត្តម សំ ប្រជាមានិត | អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | សមាជិកអចិន្ត្រៃយ៍ |
| ៦-ឯកឧត្តម ច័ន្ទ មនោ | អគ្គលេខាធិការនៃក្រសួងយុត្តិធម៌ | សមាជិក |
| ៧-ឯកឧត្តម ផូវ សំភី | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ | សមាជិក |
| ៨-ឯកឧត្តម ប៉ែន ពេជ្រសាលី | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ | សមាជិក |
| ៩-ឯកឧត្តម កើត សេកាណូ | អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ | សមាជិក។ |

គណៈកម្មការនេះ មានមន្ត្រីរាជការស្ថិតក្នុងក្របខណ្ឌក្រសួងយុត្តិធម៌មួយចំនួនតាមការចាំបាច់ ជាជំនួយការ តាមការចាត់តាំងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា ២**: គណៈកម្មការដើម្បីពិនិត្យលក្ខណវិនិច្ឆ័យសម្រាប់ការធ្វើសមាហរណកម្មទៅក្នុងថ្នាក់ និងឋានន្តរស័ក្តិនៃចៅក្រម និងព្រះរាជអាជ្ញា មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

-រៀបចំ និងកំណត់លក្ខណវិនិច្ឆ័យនៃក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់ចៅក្រម និងព្រះរាជអាជ្ញាបច្ចុប្បន្ន ដើម្បីធ្វើសមាហរណកម្មទៅក្នុងក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មី ស្របតាមព្រះរាជក្រឹត្យស្តីពីឋានន្តរស័ក្តិ និងថ្នាក់សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា

-រៀបចំ និងសម្រេចការធ្វើសមាហរណកម្មក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់ចៅក្រម និងព្រះរាជ-អាជ្ញាបច្ចុប្បន្នទៅក្នុងក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មី

-រៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការធ្វើសមាហរណកម្មនេះ ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សម្រាប់ទូលថ្វាយព្រះមហាក្សត្រ ព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

-អនុវត្តការងារផ្សេងទៀត តាមការចាំបាច់ ដើម្បីធានាដល់ការធ្វើសមាហរណកម្មចៅក្រម និងព្រះរាជ-អាជ្ញាទៅក្នុងក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មី ស្របតាមច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

**មាត្រា ៣**: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤**: ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត/០៧១៥/៧០៤

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៥*

លេខៈ ៧១៩ ស.ណ
**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៦៩៩

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ .-**

តែងតាំង និងតម្លើងឋានៈជាអគ្គនាយក អគ្គលេខាធិការ អគ្គលេខាធិការរង អគ្គាធិការ ទីប្រឹក្សាអមក្រសួង និងជំនួយការអមក្រសួងបរិស្ថាន ចំនួន ១៥រូប ៖

| | |
|---|---|
| ១-ឯកឧត្តម **ចាយ សាមិត្ត** | ជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ មានឋានៈស្មើ **រដ្ឋលេខាធិការ** |
| ២-ឯកឧត្តម **ទិន ពន្លក** | ជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានឋានៈស្មើ **រដ្ឋលេខាធិការ** |
| ៣-ឯកឧត្តម **វ័ត្ន វិរៈ** | ជាទីប្រឹក្សាអមក្រសួង មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤-ឯកឧត្តម **កែន សេរីរដ្ឋា** | ជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** |

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ក្រសួងព្រះបរមរាជវាំង

៥-ឯកឧត្តម **ឡុញ ហ៊ាល** ជាទីប្រឹក្សាអមក្រសួង មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**
៦-ឯកឧត្តម **សែម សារឿន** ជាអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
៧-ឯកឧត្តម **ហេង ណារ៉េត** ជាអគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន
៨-ឯកឧត្តម **ជួប ប៉ារីស** ជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានឋានៈស្មើ **អគ្គនាយក**
៩-ឯកឧត្តម **វ៉ាន់ មុនីនាថ** ជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានឋានៈស្មើ **អគ្គនាយក**
១០-លោកជំទាវ **ចាន់ សុម៉ាលី** ជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានឋានៈស្មើ **អគ្គនាយក**
១១-ឯកឧត្តម **ភាវ សុវុទ្ធី** ជាអគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន
១២-ឯកឧត្តម **ឈរ រតនៈ** ជាអគ្គាធិការនៃអគ្គាធិការដ្ឋាន
១៣-ឯកឧត្តម **ជឹម វង្ឋា** ជាជំនួយការអមក្រសួង មានឋានៈស្មើ **អគ្គនាយក**
១៤-ឯកឧត្តម **ហោ ស៊ីម៉ែន** ជាជំនួយការអមក្រសួង មានឋានៈស្មើ **អគ្គនាយក**
១៥-ឯកឧត្តម **សូ សិង្ហា** ជំនួយការអមក្រសួង មានឋានៈស្មើ **អគ្គនាយក**។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*នស/រកត.០៧១៥.៧០៥* **នរោត្តម សីហមុនី**

លេខ: ៧១៧ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៥*

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/ ៧២០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ ដល់ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ឯក**

១-ឧត្តមសេនីយ៍ទោ **ខេង ចណ្ណា** អត្តលេខ ០១៩៥៤១
២-ឧត្តមសេនីយ៍ទោ **ចៅ តិរិទ្ធ** អត្តលេខ ០១៣៩២០
៣-ឧត្តមសេនីយ៍ទោ **ណឹម បញ្ញាឫទ្ធ** អត្តលេខ ០០១៥៥១
៤-ឧត្តមសេនីយ៍ទោ **សូ សូច័ន្ទ** អត្តលេខ ០០១៥៦៣

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ**

១-ឧត្តមសេនីយ៍ត្រី **សុខ ម៉ិនថន** អត្តលេខ ០០១៤០៧
២-ឧត្តមសេនីយ៍ត្រី **ម៉ៅ សុគន្ធ** អត្តលេខ ០០៨៣៧៣
៣-ឧត្តមសេនីយ៍ត្រី **សំ ឌិនណាន** អត្តលេខ ០១៣៨៧៣
៤-ឧត្តមសេនីយ៍ត្រី **សួស ណារិន** អត្តលេខ ០០១៤៣៤
៥-ឧត្តមសេនីយ៍ត្រី **សូ សុវណ្ណរតនា** អត្តលេខ ០១៩៨៣៣
៦-ឧត្តមសេនីយ៍ត្រី **សោម ជោគ** អត្តលេខ ០១៣៦៩២
៧-ឧត្តមសេនីយ៍ត្រី **រ៉ូ ពិសិដ្ឋ** អត្តលេខ ០៤៣៥១៧
៨-ឧត្តមសេនីយ៍ត្រី **ប្រាក់ សុវណ្ណ** អត្តលេខ ០០១៣១៨
៩-ឧត្តមសេនីយ៍ត្រី **នៅ អំសាន្ត** អត្តលេខ ០៣១៧៧០
១០-ឧត្តមសេនីយ៍ត្រី **ផាង ផលសីលា** អត្តលេខ ០០១៩៨៨
១១-ឧត្តមសេនីយ៍ត្រី **សូ សុវណ្ណរតនៈ** អត្តលេខ ០១៤២៦២

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

១២-ឧត្តមសេនីយ៍ត្រី **ឡុត ណារ៉ា** អត្តលេខ ០១៩៨៦១
១៣-ឧត្តមសេនីយ៍ត្រី **សោម រតនា** អត្តលេខ ០០៩២៨៧
១៤-ឧត្តមសេនីយ៍ត្រី **ណា សាន់** អត្តលេខ ០០០៥៨៧
១៥-ឧត្តមសេនីយ៍ត្រី **មាស សុចិត្រា** អត្តលេខ ០៣២២៩៧
១៦-ឧត្តមសេនីយ៍ត្រី **ស៊ិន សឿន** អត្តលេខ ០០១៦១៦
១៧-ឧត្តមសេនីយ៍ត្រី **មាស រតនៈសោភ័ណ** អត្តលេខ ០៤២៩៦៧
១៨-ឧត្តមសេនីយ៍ត្រី **សន ម៉ុន** អត្តលេខ ០១៧១០១
១៩-ឧត្តមសេនីយ៍ត្រី **អ៊ិន សាឡុច** អត្តលេខ ០០៨៦០៧
២០-ឧត្តមសេនីយ៍ត្រី **ឈួន ឈាច** អត្តលេខ ០០១៥៧១
២១-ឧត្តមសេនីយ៍ត្រី **សុ រឿច** អត្តលេខ ០០១៥៦២
២២-ឧត្តមសេនីយ៍ត្រី **សេក នី** អត្តលេខ ០០១១៣៧
២៣-ឧត្តមសេនីយ៍ត្រី **ស៊ុនហ្វា សែងចាន់** អត្តលេខ ០១១០៧២
២៤-ឧត្តមសេនីយ៍ត្រី **ណែម សម្បត្តិ** អត្តលេខ ០២៨៨០៧
២៥-ឧត្តមសេនីយ៍ត្រី **មាឃ ចាន់ថន** អត្តលេខ ០០៨៨៣៧
២៦-ឧត្តមសេនីយ៍ត្រី **និន តិរម្យ** អត្តលេខ ០១៦៨៤៩
២៧-ឧត្តមសេនីយ៍ត្រី **អ៊ី រតនៈពិសេស** អត្តលេខ ០១១២២៩
២៨-ឧត្តមសេនីយ៍ត្រី **អៀច លីស័ក្តិ** អត្តលេខ ០០០៥៧២
២៩-ឧត្តមសេនីយ៍ត្រី **កុសល សុវណ្ណពិសាល** អត្តលេខ ០២១៨៦៥
៣០-ឧត្តមសេនីយ៍ត្រី **ហេង សារ៉ាន់** អត្តលេខ ០២៥១២៦
៣១-ឧត្តមសេនីយ៍ត្រី **មាស ឬទ្ធី** អត្តលេខ ០៥៧៩៥៥

**ឥ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី**

១-វរសេនីយ៍ឯក **នាង សារុន** អត្តលេខ ០០៩០៣០
២-វរសេនីយ៍ឯក **ឯក ធវីវណ្ណា** អត្តលេខ ០១៩៨៩៦
៣-វរសេនីយ៍ឯក **អេន អាន់** អត្តលេខ ០១៧០៣៤
៤-វរសេនីយ៍ឯក **ប៊ុន សំ** អត្តលេខ ០០១៤៣៨
៥-វរសេនីយ៍ឯក **ជុំ សុឃឿន** អត្តលេខ ០០៨៣៧៧
៦-វរសេនីយ៍ឯក **ម៉ុក សាខន** អត្តលេខ ០០៣៥៣៣
៧-វរសេនីយ៍ឯក **អៀត សុធន** អត្តលេខ ០០១៣៣៥
៨-វរសេនីយ៍ឯក **រស់ កុសល** អត្តលេខ ០០១៤៦៩
៩-វរសេនីយ៍ឯក **ផ្លូង តេង** អត្តលេខ ០១៦៦៥០
១០-វរសេនីយ៍ឯក **រ៉ូ ពិសិត** អត្តលេខ ០២៤៥២៨
១១-វរសេនីយ៍ឯក **ឆេង ឃុន** អត្តលេខ ០៤៣២២២

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នសរកត.១៥០៧-៧០៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥

លេខ: ៧១៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៧០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ត្រាស់បង្គាប់**

**តែងតាំង :**

លោកជំទាវ **មុំ ថាវី ស៊ិន សុខណា**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៦៧.១៥០៧-៧០៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៥*

លេខ:៧១៨ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៧៦២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**នូវ**

គ្រឿងឥស្សរិយយស **ជាតូបការ** :

លោកជំទាវ **ម៉ុំ ថាវី ស៊ិន សុខណា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៦ល-១៥០៧-៧០៨

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៥*

លេខ: ៧១៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៧១៥/៧០៣

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

## ប្រោសព្រះរាជទាន

នូវ

**ក-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្សកុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :**

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្តមឧត្តមមហាទាន | ចៅ ចន្ទគាសា | ៦- | លោក | នីម នីរ៉ាជេត |
| ២- | លោកជំទាវ | លាច ទិសុទ្ធ | ៧- | លោក | នាយ គ្រូលន់ |
| ៣- | ឯកឧត្តម | លឹម គង់ | ៨- | លោក | រ៉ុង តិរច្ឆ |
| ៤- | លោកជំទាវ | ផុន ផល្លា | ៩- | លោក | ឈួន សារិន |
| ៥- | លោក | លី សេងមេង | ១០- | លោក | ម៉ៅ លី |

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

| | | | | | |
|---|---|---|---|---|---|
| ១- | លោកជំទាវ | សុខ ជាទី | ៧- | លោក | ឱក រ៉េត |
| ២- | លោកជំទាវ | ផេង រិទ្ធិកំរុត្ត | ៨- | លោក | លាង ហាក់ |
| ៣- | លោកស្រី | សរ គន្ធពិដោរ | ៩- | លោក | មឿង អួន |
| ៤- | លោក | តុង បូរិន | ១០- | លោក | ជាត់ សំផេង |
| ៥- | កញ្ញា | ម៉ង់ តារា | ១១- | លោក | សៀ សេងហ៊ាប |
| ៦- | លោកស្រី | យ៉ីម តានយី | | | |

៣ភស. ១៥០៧. ៣២៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥

លេខៈ៧១៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/ ៧៤០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**ដូច**

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-លោកវរសេនីយ៍ឯក **សេង សារិ** ២-លោកវរសេនីយ៍ឯក **សាគុណ រិទ្ធី**

៣-លោកវរសេនីយ៍ឯក **ស៊ីង សារ៉ាពេជ្រ** ៤-លោកវរសេនីយ៍ឯក **សារុំ សារ៉ាឧត្តម**

៥-លោកវរសេនីយ៍ឯក **ជិន សីហា** ៦-លោកវរសេនីយ៍ឯក **ឃួន ម៉ាន់ថេន**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១-លោកវរសេនីយ៍ឯក **ពៅ ជីវី** ២-លោកវរសេនីយ៍ឯក **ខុន ម៉ារ៉ា**

៣-លោកវរសេនីយ៍ត្រី **ឆេង សុផាន** ៤-លោក **ស្រេង វ៉ន**

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :**

១-លោកវរសេនីយ៍ត្រី **ខាន សារមេត** ២-លោក **អ៊ុង ស៊ីណាត**

**ឃ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ូ សាគុណ** ២-ឯកឧត្តមឧត្តមសេនីយ៍ទោ **ឡោ សុឡេង**

៣-លោក **ឱុច គន្ធា**

**ង-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :**

លោក **អ៊ុយ សាគុណ**

**ច-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

លោកជំទាវ **សោម សុគារី**

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**ឆ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ  ថ្នាក់ មហាសេនា :**

១-លោកវរសេនីយ៍ឯក **សាន ស៊ីណា**
២-លោកវរសេនីយ៍ទោ **ខែ គួន**
៣-លោកវរសេនីយ៍ទោ **ស៊ាង ម៉េង**
៤-លោកវរសេនីយ៍ត្រី **ជឹម តិរុណ**
៥-លោកស្រីវរសេនីយ៍ត្រី **សាគុណ លីនដា**
៦-លោកអនុសេនីយ៍ទោ **ឡុង ចំរុង**
៧-លោក **លីនី តិដែន**

**ជ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :**

លោកឧត្តមសេនីយ៍ត្រី **ខូ ហាក់**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*នសរក. ១៥០៧-៧២០*

លេខ:៧១៣ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៥*

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី០៦ ខែកក្កដាឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៩៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានដំឡើងវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីថ្នាក់នាយកដ្ឋាន ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា២.-**

វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការងារបណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាពមន្ត្រីរាជការ លើមុខជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានបេសកកម្ម ដូចខាងក្រោម÷

- អនុវត្តការបណ្តុះបណ្តាល និងវិក្រឹតការ លើការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមទាំងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមបច្ចេកវិទ្យាព័ត៌មាន ជូនមន្ត្រីរាជការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវ និងប្រមូលធាតុចូលស្តីពីការអនុវត្តគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ពង្រឹង និងកែលម្អការអនុវត្តការងារបណ្តុះបណ្តាល សំដៅលើកកម្ពស់ការយល់ដឹងជូនមន្ត្រីរាជការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធទិន្នន័យបច្ចេកវិទ្យាព័ត៌មាន សម្រាប់គាំទ្រការកសាង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទំនាក់ទំនងជាប្រចាំជាមួយគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័ន ដើម្បីពិគ្រោះវាយតម្លៃប្រសិទ្ធភាព និងកំណត់អំពីតម្រូវការនៃការស្រាវជ្រាវ ការហ្វឹកហ្វឺន ការបណ្តុះបណ្តាល និងវិក្រឹតការ
- ផ្តួចផ្តើម សម្របសម្រួល និង ជំរុញកិច្ចសហប្រតិបត្តិការលើការងារស្រាវជ្រាវ និងបណ្តុះបណ្តាល ជាមួយនឹងស្ថាប័នស្រាវជ្រាវ និងគ្រឹះស្ថានអប់រំជាតិ និងអន្តរជាតិ ដើម្បីធ្វើទំនើបកម្មកម្មវិធីស្រាវជ្រាវ បណ្តុះបណ្តាល និងវិក្រឹតការ និង លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បោះពុម្ព និងផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវ និងឯកសារសិក្សាសំខាន់ៗ ពាក់ព័ន្ធនឹងបញ្ហាសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំ និង សម្របសម្រួលការផ្ទេរ និង ចែករំលែកចំណេះដឹង ជំនាញ និងឧត្តមានុវត្តន៍ពីទីប្រឹក្សា និងអ្នកជំនាញការ ទាំងក្នុងស្រុក និងអន្តរជាតិ ជូនដល់មន្ត្រីរាជការ គ្រូបង្គោល គ្រូឧទ្ទេស និងសាស្ត្រាចារ្យ
- រៀបចំរបាយការណ៍ស្តីពីសកម្មភាពនៃការស្រាវជ្រាវ ការហ្វឹកហ្វឺន ការបណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាពមន្ត្រីរាជការ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា៣.-**

វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយនាយកមួយរូប មានឋានៈ និង បុព្វសិទ្ធិស្មើអគ្គនាយក និង អមដោយនាយករង មួយចំនួន មានបុព្វសិទ្ធិ និងឋានៈស្មើអគ្គនាយករង ជាជំនួយការ ។

នាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និង អមដោយអនុប្រធានមួយចំនួន ជាជំនួយការ ។

អង្គការលេខរបស់វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា៤.-**

វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរចនាសម្ព័ន្ធដូចខាងក្រោម ÷

- នាយកដ្ឋានបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ
- នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ
- នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍ ។

**មាត្រា៥.-**

នាយកដ្ឋានបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការងារគ្រប់គ្រងបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ។

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ បំពេញការងារជាសេនាធិការឱ្យវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការងារគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាល គ្រូបង្គោល គ្រូឧទ្ទេស សាស្ត្រាចារ្យ និងទំនាក់ទំនងសាធារណៈ ។

នាយកដ្ឋានស្រាវជ្រាវ និង អភិវឌ្ឍ បំពេញការងារជាសេនាធិការឱ្យវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការងារសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ ។

**មាត្រា៦.-**

ការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៧.-**

ត្រូវបានលុបបទប្បញ្ញត្តិមួយចំនួន នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចខាងក្រោម÷

- មាត្រា៧ កថាខណ្ឌទី ៥
- ពាក្យ "វិទ្យាស្ថាន" ដែលមានចែងក្នុងមាត្រា ៨
- ពាក្យ "ការបណ្តុះបណ្តាល និងវិក្រឹតការ" ដែលមានចែងក្នុងមាត្រា ១០ ត្រង់ទី ៣
- ពាក្យ "និង មន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ" ដែលមានចែងក្នុងមាត្រា ១១ ត្រង់ទី ៦
- មាត្រា ១១ ត្រង់ទី ៧
- មាត្រា ១២ ត្រង់ទី ៦
- មាត្រា ១៣ កថាខណ្ឌទី ៦ ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ .៩៤៥.... អនក្រ.បក ចុះថ្ងៃទី២៣. ខែ កក្កដា.... ឆ្នាំ ២០១៥

អង្គការលេខរបស់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ :...៧២...អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣៣៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាពីជំពូក៦១ (សេវាកម្ម) ចំនួន ៦៨ ០០០ ០០០រៀល មកជំពូក៦៥ (ឧបត្ថម្ភកធន) ចំនួន ៦៨ ០០០ ០០០រៀល ជូនក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ជួសជុល និង ថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ** :...៩៧...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥, ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក, ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣៣៦ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាពីជំពូក៦០(ការទិញ) ចំនួន ៧៦ ៥០០ ០០០រៀល មកជំពូក៦១ (សេវាកម្ម) ចំនួន៧៦ ៥០០ ០០០រៀល ជូនមន្ទីរកសិកម្មខេត្តបាត់ដំបង និងខេត្តសៀមរាប នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ នេសាទ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាផ្ទេរក្នុងជំពូកនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៤ ខែកក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៩៤..អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងអាងទន្លេ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹកនិងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹកនិងឧតុនិយម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍអាងទន្លេឱ្យមានប្រសិទ្ធភាពនិងនិរន្តរភាពដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីនីតិវិធីនៃការរៀបចំ និងការអនុវត្តផែនការនៃការគ្រប់គ្រងការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ អាងទន្លេរង ទឹកលើដីជម្រាល ទឹកក្រោមដី និងល្អាងទឹកក្រោមដី។

**មាត្រា៣ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តលើគ្រប់អាងទន្លេក្នុងព្រះរាជាណាចក្រកម្ពុជា [illegible]ការជាមួយប្រទេសជិតខាងក្នុងការប្រើប្រាស់ទឹកលើគ្រប់វិស័យ។

**មាត្រា៤ .-**

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងអនុក្រឹត្យនេះ រួមមាន៖

| | |
|---|---|
| អាងទន្លេ | សំដៅដល់តំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរដោយរាប់បញ្ចូលទាំងទឹកលើដីនិងទឹកក្រោមដី។ |
| អាងទន្លេរង | សំដៅដល់ផ្នែកមួយនៃអាងទន្លេ។ |
| ទឹកក្រោមដី | សំដៅដល់ទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូចធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត។ |
| ល្អាងទឹកក្រោមដី | សំដៅដល់ទឹកក្រោមដី ដែលស្ថិតនៅជាអចិន្ត្រៃយ៍ល្អាងធម្មជាតិក្រោមដី។ |
| សមុទ្រ | សំដៅដល់ប្រភពធនធានទឹកប្រៃ និងជាកន្លែងទទួលហូរទឹកមកពីទន្លេ ស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ។ |
| ទន្លេ | សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅសមុទ្រ។ |
| ស្ទឹង | សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅបឹង ទន្លេ និងសមុទ្រ។ |
| ព្រែក | សំដៅដល់ផ្លូវទឹកធម្មជាតិឬសិប្បនិម្មិត ដែលនាំទឹកចេញឬចូលពីទន្លេឬស្ទឹង និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ។ |
| អូរ | សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីជ្រោះ និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចូលព្រែក ស្ទឹង ទន្លេ ឬបឹង។ |
| ជ្រោះ | សំដៅដល់ជ្រលងឬល្បាក់ទឹកធម្មជាតិ ដែលកើតឡើងដោយសារបាតុភូតធម្មជាតិនៃការហូរច្រោះដោយសារចរន្តទឹកពីតំបន់ភ្នំឬតំបន់ខ្ពង់រាប។ |
| បឹងបួ | សំដៅដល់ល្ហាលទឹកធំល្វឹងល្វើយកើតពីទីជម្រាលឬជម្រៅធម្មជាតិ ដែលអាចមានទឹកឬគ្មានទឹកទៅតាមរដូវកាល និងមានប្រភពទឹកមកពីទន្លេ ស្ទឹង ព្រែក ឬពីតំបន់ផ្ទៃរងទឹកភ្លៀង។ |
| អាងទឹក | សំដៅដល់ទីតម្កល់ទឹកដែលកើតឡើងដោយធម្មជាតិឬសិប្បនិម្មិតសម្រាប់ប្រើទៅតាមតម្រូវការ។ |
| ឆ្នេរ សមុទ្រ ទន្លេ ស្ទឹង | សំដៅដល់ចំណែកដីឬខ្សាច់ដែលមានសណ្ឋានជម្រាល និងលិចទឹកម្តងម្កាល។ |
| ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក | សំដៅដល់ចំណែកដីដែលធម្មតាលិចដោយទឹកនៅក្នុងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក ដោយរាប់បញ្ចូលទាំងដី ថ្ម ឬអង្គធាតុដទៃទៀត ដែលជាប់នៅនឹង ច្រាំងនោះដោយមិនរាប់បញ្ចូលនូវដី ថ្ម ឬអង្គធាតុដទៃទៀត ដែលនៅឆ្ងាយពីច្រាំងនិងលិចទឹកម្តងម្កាលនោះទេ។ |
| មាត់ច្រាំង | សំដៅដល់ខ្សែបន្ទាត់ក្រិតកម្ពស់ទឹកខ្ពស់បំផុតនៅរដូវវស្សា លើកលែងតែករណីដែលមានទឹកជំនន់ខុសធម្មតា។ |
| មាត់ឆ្នេរ | សំដៅដល់ខ្សែបន្ទាត់ក្រិតកម្ពស់ទឹកជោរខ្ពស់បំផុតនៅសម[illegible] |

| | |
|---|---|
| **ពាមសមុទ្រ** | សំដៅដល់តំបន់ចុងក្រោយនៃទន្លេ ស្ទឹង ព្រែក ដែលប្រសព្វជាមួយនឹងសមុទ្រ។ |
| **រក្សាលំហូរ** | សំដៅដល់របបលំហូរទឹកអប្បបរមាចាំបាច់ដែលត្រូវរក្សាឱ្យមាននៅក្នុងទន្លេ ស្ទឹង ព្រែក ដើម្បីធានាបាននូវនិរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ី និងផលប្រយោជន៍ផ្សេងៗទៀត។ |
| **តំបន់ហានិភ័យ** | សំដៅដល់តំបន់ដែលងាយរងនូវការប៉ះពាល់ឬការខូចខាតធ្ងន់ធ្ងរដែលបណ្តាលមកពីកត្តាមនុស្សនិងធម្មជាតិ។ |
| **ទន្លេអន្តរជាតិ** | សំដៅដល់ទន្លេដែលមានភូមិសាស្ត្រពាក់ព័ន្ធដល់ទឹក ដី ប្រទេសចាប់ពីពីរឡើងទៅ។ |

## ជំពូកទី២
## គោលការណ៍នៃការគ្រប់គ្រងអាងទន្លេ

**មាត្រា៥ .-**

ដើម្បីគ្រប់គ្រងអាងទន្លេនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យមានតុល្យភាព ប្រសិទ្ធភាព និងនិរន្តរភាព គោលការណ៍មួយចំនួនត្រូវបានកំណត់ដូចខាងក្រោម៖

- គ្រប់គ្រងប្រភពទឹកដើម្បីបម្រើដល់ការប្រើប្រាស់ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹកនៅក្នុងអាងទន្លេ
- គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានទឹកដោយឈរលើមូលដ្ឋាននៃទស្សនាទាន និងវិធីសាស្ត្រស្តីពីការគ្រប់គ្រងធនធានទឹកចម្រុះដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- គ្រប់គ្រងធនធានទឹកក្នុងអាងទន្លេ ដោយមិនគិតពីព្រំដែនរដ្ឋបាល និងស្ថិរភាពរវាងផ្នែកខាងលើនិងផ្នែកខាងក្រោមដោយឈរលើគោលការណ៍សមធម៌និងសង្គតិភាព
- រក្សាលំហូរទឹកអប្បបរមានៃផ្លូវទឹក និងនិរន្តរភាពកម្រិតកម្ពស់ទឹកក្រោមដី រួមចំណែកទ្រទ្រង់ដល់ប្រព័ន្ធអេកូឡូស៊ី
- គ្រប់គ្រងធនធានទឹកក្នុងអាងទន្លេអន្តរជាតិ ដោយឈរលើកិច្ចព្រមព្រៀងអន្តរជាតិ គោរពអធិបតេយ្យភាពជាតិ និងគោរពផលប្រយោជន៍គ្នាទៅវិញទៅមក
- អភិវឌ្ឍនិងប្រើប្រាស់ធនធានទឹកឱ្យមានសង្គតិភាពជាមួយនឹងធនធានធម្មជាតិដទៃទៀតដែលមាននៅក្នុងអាងទន្លេ
- បែងចែកការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពនិងសមភាព
- រួមចំណែកលើកស្ទួយកម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដោយគិតគូរលើបរិមាណនិងគុណភាពទឹក
- លើកទឹកចិត្តដល់ការអភិរក្សនិងការអភិវឌ្ឍធនធានទឹកក្នុងអាងទន្លេ
- សហការជាមួយប្រទេសជិតខាងក្នុងការប្រើប្រាស់ទឹកលើគ្រប់វិស័យ។

## ជំពូកទី៣
## ការកំណត់តំបន់អាងទន្លេ ដីចំណីមាត់ច្រាំង និងឆ្នេរ

**មាត្រា៦ .-**

យោងតាមលក្ខណៈភូមិសាស្ត្រនិងរបបជលសាស្ត្រ អាងទន្លេនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានចំនួន៣៩(សាមសិបប្រាំបួន) ដែលត្រូវបានកំណត់ជា៧(ប្រាំពីរ)តំបន់។

ផែនទីកំណត់តំបន់អាងទន្លេនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានចែងក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

តារាងឈ្មោះនិងទំហំផ្ទៃអាងទន្លេនីមួយៗមានចែងក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា៧ .-**

ក្រសួងធនធានទឹកនិងឧតុនិយម ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំធ្វើបញ្ជីសារពើភណ្ឌអាងទន្លេ រួមមានតំបន់ឆ្នេរ ទន្លេ ស្ទឹង ព្រែក បឹង អាងទឹក និងល្អាងទឹកក្រោមដី។ បញ្ជីសារពើភណ្ឌនេះបង្ហាញពីឈ្មោះ ទីតាំង ព្រំដែន បរិមាណ និងគុណភាពនៃធនធានទាំងនោះ។

បញ្ជីសារពើភណ្ឌអាងទន្លេត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម។

**មាត្រា៨ .-**

ដីចំណីមាត់ច្រាំងនិងឆ្នេរនៃតំបន់អាងទន្លេត្រូវកំណត់ចម្ងាយដូចតទៅ៖

- ឆ្នេរនិងពាមសមុទ្រ ចម្ងាយ១០០(មួយរយ)ម៉ែត្រគិតពីមាត់ឆ្នេរនិងមាត់ពាម(ពេលទឹកជោរអតិបរមា)

| | |
|---|---|
| - ទន្លេ | ចម្ងាយ៥០(ហាសិប)ម៉ែត្រ គិតពីមាត់ច្រាំងទន្លេ |
| - ស្ទឹង | ចម្ងាយ៣០(សាមសិប)ម៉ែត្រ គិតពីមាត់ច្រាំងស្ទឹង |
| - ព្រែក | ចម្ងាយ២០(ម្ភៃ)ម៉ែត្រ គិតពីមាត់ច្រាំងព្រែក |
| - អូរ | ចម្ងាយ១០(ដប់)ម៉ែត្រ គិតពីមាត់ច្រាំងអូរ |
| - ប្រឡាយមេ | ចម្ងាយ១០(ដប់)ម៉ែត្រ គិតពីជើងទេរភ្លឺប្រឡាយផ្នែកខាងក្រៅ |
| - ប្រឡាយរង | ចម្ងាយ៥(ប្រាំ)ម៉ែត្រ គិតពីជើងទេរភ្លឺប្រឡាយផ្នែកខាងក្រៅ |
| - ប្រឡាយស្រោចស្រព | ចម្ងាយ៣(បី)ម៉ែត្រ គិតពីជើងទេរភ្លឺប្រឡាយផ្នែកខាងក្រៅ |
| - អាងទឹក | ចម្ងាយ១០០(មួយរយ)ម៉ែត្រគិតពីក្រិតកម្ពស់ទឹកអតិបរមាដែលបានតម្កល់នៅក្នុងអាងទឹក |
| - បឹងបួ | ចម្ងាយ៥០(ហាសិប)ម៉ែត្រគិតពីក្រិតកម្ពស់ទឹកអតិបរមាដែលបានតម្កល់នៅក្នុងអាងទឹក |
| - ទំនប់អាងទឹក | ចម្ងាយ២០(ម្ភៃ)ម៉ែត្រ គិតពីជើងទេរផ្នែកខាងក្រោមទំនប់អាងទឹកដែលមានកម្ពស់តិចជាង៤(បួន)ម៉ែត្រ។ ចម្ងាយ១០០(មួយរយ)ម៉ែត្រ គិតពីជើងទេរផ្នែកខាងក្រោមទំនប់អាងទឹកដែលមានកម្ពស់ពី៤(បួន)ម៉ែត្រទៅ៨(ប្រាំបី)ម៉ែត្រ។ ក្នុងករណីទំនប់ដែលមានកម្ពស់លើសពី៨(ប្រាំបី)ម៉ែត្រឡើងទៅត្រូវបានកំណត់អនុក្រឹត្យដោយឡែក។ |

ដីចំណីមាត់ច្រាំង ឆ្នេរ និងពាមសមុទ្រនៅតំបន់រាជធានីឬក្រុងនៃខេត្តឬទីប្រជុំជន និងតំបន់អភិវឌ្ឍត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

ដីចំណីមាត់ច្រាំង ឆ្នេរ និងពាមសមុទ្រនៃតំបន់អាងទន្លេបានកំណត់ខាងលើជាសម្បត្តិសាធារណៈរបស់រដ្ឋ។

ការកំណត់ដីចំណីមាត់ច្រាំងនិងឆ្នេរខាងលើគ្មានអានុភាពប្រតិសកម្ម  ពេលអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា៩ .-**

ស្ថានភាពបច្ចុប្បន្ននិងហានិភ័យចំពោះធនធានទឹកក្នុងអាងទន្លេ ត្រូវបានធ្វើចំណាត់ថ្នាក់ជា៣(បី)កម្រិត ដូចខាងក្រោម៖

- **កម្រិត១ :** ធនធានទឹកដែលទទួលរងហានិភ័យដោយមិនបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

- **កម្រិត២** : ធនធានទឹកដែលទទួលរងហានិភ័យដោយបង្កផលប៉ះពាល់ ខូចខាត និងគំរាមកំហែងជាយថាហេតុក្នុងរយៈពេលខ្លីដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- **កម្រិត៣** : ធនធានទឹកដែលរងហានិភ័យដោយបង្កមហន្តរាយធ្ងន់ធ្ងរ និងយូរអង្វែងដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

ចំណាត់ថ្នាក់ហានិភ័យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម។

## ជំពូកទី៤
## សមត្ថកិច្ចនិងយន្តការនៃការគ្រប់គ្រងអាងទន្លេ

**មាត្រា១០ .-**

ក្រសួងធនធានទឹកនិងឧតុនិយម ជាស្ថាប័នមានសមត្ថកិច្ចដឹកនាំ ត្រួតពិនិត្យ និងសម្របសម្រួលក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ ស្របតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១១ .-**

ដើម្បីគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍអាងទន្លេនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព ត្រូវរៀបចំយន្តការដូចខាងក្រោម៖

១- រៀបចំបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ។

២- រៀបចំបង្កើតគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ។

**មាត្រា១២ .-**

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ មានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | អនុប្រធាន |
| ៣- រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន១រូប | អនុប្រធាន |
| ៤- រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| ៥- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប | សមាជិក |
| ៦- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប | សមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម១រូប | សមាជិក |
| ១០- រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល១រូប | សមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប | សមាជិក |
| ១២- រដ្ឋលេខាធិការក្រសួងទេសចរណ៍១រូប | សមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប | សមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងផែនការ១រូប | សមាជិក |
| ១៥- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប | សមាជិក |
| ១៦- រដ្ឋលេខាធិការក្រសួងសុខាភិបាល១រូប | សមាជិក |
| ១៧- តំណាងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា១រូប | សមាជិក |

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា១៣ .-**

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេមានតួនាទីនិងភារកិច្ច ដូចខាងក្រោមៈ

- រៀបចំគោលការណ៍ណែនាំដល់គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេក្នុងការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេស្របតាមគោលនយោបាយជាតិនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិលើវិស័យធនធានទឹក ព្រមទាំងអនុម័តលើផែនការទាំងនោះ

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ

- សម្របសម្រួលក្នុងការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធដែលអាស្រ័យផលពីធនធានទឹកក្នុងអាងទន្លេលើការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ

- ជូនដំណឹងឱ្យបានទាន់ពេលវេលាដល់ប្រជាជនក្នុងបូលដ្ឋានអំពីសកម្មភាពនានាដែលទាក់ទងនឹងទឹក

- សម្របសម្រួលនិងដោះស្រាយវិវាទនានានៅក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ

- រក្សាទុកឯកសារ និងព័ត៌មាននានាស្តីពីបញ្ហា និងសកម្មភាពធនធានទឹកក្នុងអាងទន្លេ

- សហការជាមួយនឹងក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធដើម្បីសិក្សានិងស្រាវជ្រាវទាក់ទងនឹងការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ

- រៀបចំរបាយការណ៍ប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល

- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា១៤ .-**

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវប្រជុំយ៉ាងតិច១(មួយ)ដង ក្នុងមួយឆ្នាំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ប្រធានត្រូវផ្ទេរសិទ្ធិជូនអនុប្រធានដើម្បីដឹកនាំអង្គប្រជុំ។

ក្នុងករណីចាំបាច់ ប្រធានអាចអញ្ជើញតំណាងមកពីក្រសួង ស្ថាប័នផ្សេងៗ មន្ត្រីជំនាញ អ្នកបច្ចេកទេស ឬតំណាងវិស័យឯកជន ដើម្បីចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ឬការស្រាវជ្រាវបញ្ហាទាក់ទងនឹងសកម្មភាពពាក់ព័ន្ធការគ្រប់គ្រងអាងទន្លេ។

**មាត្រា១៥ .-**

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេមានលេខាធិការដ្ឋានមួយ ដែលមានទីតាំងនៅក្នុងក្រសួងធនធានទឹកនិងឧតុនិយមសម្រាប់កិច្ចដំណើរការសកម្មភាពរបស់ខ្លួន។

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេមានសិទ្ធិប្រើត្រារបស់ក្រសួងធនធានទឹកនិងឧតុនិយម

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ ដឹកនាំដោយប្រធានលេខាធិការដ្ឋានមួយរូបនិងមានអនុប្រធានលេខាធិការដ្ឋានមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម។

**មាត្រា១៦ .-**

គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេមានសមាសភាពដូចតទៅ៖

| | |
|---|---|
| - អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ប្រធាន |
| - អភិបាលរងរាជធានី ខេត្ត | អនុប្រធាន |
| - ប្រធានមន្ទីរធនធានទឹកនិងឧតុនិយម | សមាជិកអចិន្ត្រៃយ៍ |
| - ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - ប្រធានមន្ទីរកសិកម្ម | សមាជិក |
| - ប្រធានមន្ទីរបរិស្ថាន | សមាជិក |
| - ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូន | សមាជិក |
| - ប្រធានមន្ទីរឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| - ប្រធានមន្ទីររ៉ែនិងថាមពល | សមាជិក |
| - ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | សមាជិក |
| - ប្រធានមន្ទីរទេសចរណ៍ | សមាជិក |
| - ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី | សមាជិក |
| - ប្រធានមន្ទីរផែនការ | សមាជិក |
| - នាយខណ្ឌរដ្ឋបាលព្រៃឈើ | សមាជិក |
| - នាយខណ្ឌរដ្ឋបាលជលផល | សមាជិក |
| - អភិបាលស្រុក ខណ្ឌ ក្រុង មេឃុំ ចៅសង្កាត់ដែលមានការពាក់ព័ន្ធ | សមាជិក។ |

ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការអាចអញ្ជើញមន្ត្រីជំនាញ ឬបុគ្គលដែលតំណាងឱ្យសហគមន៍ផ្សេងៗទៀត ដែលបានទទួលផលក្នុងអាងទន្លេឱ្យចូលរួមជាអ្នកសង្កេតការណ៍នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការខាងលើ។

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ។

**មាត្រា១៧ .-**

គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ ត្រូវមានលេខាធិការដ្ឋានមួយដើម្បីធានាដល់កិច្ចដំណើរការឱ្យមានប្រសិទ្ធភាពខ្ពស់និងអាចប្រើត្រាដោយឡែករបស់ខ្លួន។ លេខាធិការដ្ឋានមានទីតាំងស្ថិតនៅក្នុងមន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្តដែលមានអភិបាលនៃគណៈអភិបាលរាជធានី ខេត្តជាប្រធានគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ។ ប្រធានមន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្ត នេះជាប្រធានលេខាធិការដ្ឋាន។

គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេត្រូវកោះប្រជុំយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំ។ ក្នុងករណីចាំបាច់ អាចកោះប្រជុំជាវិសាមញ្ញបាន។

ប្រធានគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ ត្រូវរាយការណ៍ពីលទ្ធផលការងារកិច្ចប្រជុំនិងសកម្មភាពការងារប្រចាំឆ្នាំជូនប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ។

**មាត្រា១៨ .-**

គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេមានតួនាទីនិងភារកិច្ចដូចតទៅៈ

- រៀបចំបទបញ្ញាផ្ទៃក្នុង និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការអភិរក្ស ការបែងចែកទឹក ការស្តារឡើងវិញ និងការអភិវឌ្ឍអាងទន្លេស្របតាមគោលនយោបាយជាតិលើវិស័យធនធានទឹក
- បញ្ជូនរាល់ផែនការទៅគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ ដើម្បីពិនិត្យនិងសម្រេច
- តាមដាននិងសម្របសម្រួលរាល់សកម្មភាពទាំងអស់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តផែនការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍអាងទន្លេ
- បន្តណែនាំអំពីវិធានការសម្រាប់ការពារបរិស្ថានទឹក ការធ្វើអាជីវកម្ម ការប្រើប្រាស់និងការអភិវឌ្ឍធនធានទឹក និងវិធានការសម្រាប់បង្ការហានិភ័យ និងការកាត់បន្ថយគ្រោះអាសន្នដែលបង្កដោយទឹកក្នុងអាងទន្លេ
- បន្តណែនាំអំពីវិធានការដល់ភ្នាក់ងារជំនាញ ដើម្បីឆ្លើយតបនឹងសកម្មភាពនានា ដែលបំពុលបរិស្ថានទឹក
- ជូនដំណឹងដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងអាងទន្លេឱ្យបានទាន់ពេលវេលាអំពីគ្រោះអាសន្នបណ្តាលមកពីទឹក
- សម្របសម្រួលនិងដោះស្រាយរាល់ទំនាស់នានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេប្រគល់ជូន។

**មាត្រា១៩ .-**

លេខាធិការដ្ឋាននៃគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេមានតួនាទីនិងភារកិច្ចដូចតទៅៈ

១- ផ្តល់ការគាំទ្រផ្នែករដ្ឋបាលនិងការសម្របសម្រួលផ្នែកហិរញ្ញវត្ថុដល់គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេក្នុងការរៀបចំផែនការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍអាងទន្លេ។

២- សម្របសម្រួលក្នុងការប្រមូលព័ត៌មាន ការចងក្រងប្រព័ន្ធទិន្នន័យ និងការរៀបចំរបាយការណ៍ជូនគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ។

៣- តាមដាននិងត្រួតពិនិត្យការអនុវត្តសេចក្តីសម្រេចនានា ដែលបានដាក់ចេញដោយគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ។

៤- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេប្រគល់ជូន។

**មាត្រា២០ .-**

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេនិងគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេត្រូវមានថវិកាសម្រាប់ដំណើរការរដ្ឋបាល។ ថវិកានេះត្រូវស្ថិតក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងធនធានទឹក និងឧតុនិយមនិងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ។

## ជំពូកទី៥
## ផែនការគ្រប់គ្រងអាងទន្លេ

**មាត្រា២១ .-**

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេឱ្យស្របតាមគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងកម្មវិធីវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល

ក្នុងការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវចាត់ឱ្យមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយពីក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ ហើយអនុម័តលើផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពទាំងនេះដើម្បីធ្វើការបោះពុម្ពផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធនានា។

**មាត្រា២២ .-**

ការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ ត្រូវពិនិត្យពិចារណាដោយឈរលើគោលការណ៍ដូចមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យនេះ។

**មាត្រា២៣ .-**

អាណត្តិរបស់ផែនការមេមានសុពលភាពពី១០(ដប់)ទៅ១៥(ដប់ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃទទួលបានការអនុម័តពីគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ។

អាណត្តិរបស់ផែនការយុទ្ធសាស្ត្រមានសុពលភាពពី៣(បី)ទៅ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃទទួលបានការអនុម័តពីគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ។

អាណត្តិរបស់ផែនការសកម្មភាពមានសុពលភាពពី១(មួយ)ទៅ៣(បី)ឆ្នាំ គិតចាប់ពីថ្ងៃទទួលបានការអនុម័តពីគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ។

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវដឹកនាំ សម្របសម្រួល ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តផែនការគ្រប់គ្រងអាងទន្លេ រៀងរាល់ឆមាសនៃឆ្នាំនីមួយៗ។

ក្នុងករណីដែលការអនុវត្តផែនការគ្រប់គ្រងអាងទន្លេដំណើរការបានល្អ គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេអាចពន្យារសុពលភាពបន្តបាន ប៉ុន្តែមិនត្រូវលើសពី៥(ប្រាំ)ឆ្នាំ គិតពីថ្ងៃដែលអាណត្តិរបស់ផែនការគ្រប់គ្រងអាងទន្លេអស់សុពលភាព។ រាល់ផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេណាមួយដែលពិនិត្យឃើញថា មិនអាចអនុវត្តបន្តទៅមុខបាន គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវណែនាំឱ្យរៀបចំកែសម្រួលជាថ្មីឡើងវិញ ស្របតាមកាលានុវត្តភាព។

នីតិវិធីនៃការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម។

## ជំពូកទី៦
## វិធានការគ្រប់គ្រងអាងទន្លេ

**មាត្រា២៤ .-**

វិធានការសំខាន់ៗសម្រាប់គ្រប់គ្រងអាងទន្លេមានការគ្រប់គ្រងបរិមាណនិងគុណភាពទឹក ការការពារប្រភពទឹក ការបង្ការនិងកាត់បន្ថយគ្រោះអាសន្នបង្កឡើងដោយទឹក។

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ ត្រូវរៀបចំសៀវភៅណែនាំលម្អិតស្ដីពីគោលការណ៍ និងវិធានការនៃការគ្រប់គ្រងអាងទន្លេ។

**មាត្រា២៥ .-**

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេនិងគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ ត្រូវរៀបចំអនុវត្តការត្រួតពិនិត្យនិងការវាយតម្លៃធនធានទឹក និងធនធានពាក់ព័ន្ធ។

សកម្មភាពសម្រាប់ត្រួតពិនិត្យនិងការវាយតម្លៃធនធានទឹក និងធនធានពាក់ព័ន្ធនៅក្នុងអាងទន្លេ រួមមាន៖

- ធ្វើអង្កេតនិងធ្វើបញ្ជីសារពើភណ្ឌធនធានទឹក ដោយផ្ដោតទៅលើបរិមាណនិងគុណភាពទឹកលើដីនិងក្រោមដីក្នុងអាងទន្លេនីមួយៗ
- ធ្វើអង្កេតអំពីបរិស្ថានពាក់ព័ន្ធនឹងធនធានទឹកក្នុងអាងទន្លេ ដោយគិតបញ្ចូលទាំងការត្រួតពិនិត្យអំពីផលប៉ះពាល់ដែលអាចកើតមានឡើងពីការប្រែប្រួលអាកាសធាតុ
- រៀបចំចងក្រងទិន្នន័យនិងព័ត៌មានដោយធ្វើផែនទីស្ដីពីស្ថានភាពអាងទន្លេ ផែនទីអភិរក្សធនធានទឹក ផែនទីទឹកក្រោមដី រួមទាំងផែនទីតំបន់ប្រភពទឹកសម្រាប់បំពេញទឹកក្រោមដីឡើងវិញ
- រៀបចំបញ្ជីកំណត់ទីតាំងធនធានទឹកដែលរងការបំពុល ការថយចុះបរិមាណ គុណភាព និងការធ្វើអាជីវកម្មទឹកហួសកម្រិត
- ជូនដំណឹងជាមុនអំពីព្រឹត្តិការណ៍នានាដែលពាក់ព័ន្ធនឹងធនធានទឹក អង្កេតអំពីស្ថានភាពបច្ចុប្បន្ននៃការធ្វើអាជីវកម្មទឹក ការប្រើប្រាស់ធនធានទឹក និងការបង្ហូរទឹកសំណល់ចូលប្រភពទឹកក្នុងអាងទន្លេ
- បង្កើតនិងរក្សាទុកនូវប្រព័ន្ធព័ត៌មាននិងមូលដ្ឋានទិន្នន័យ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ ៥៧ អនក្រ.បក
ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងអាងទន្លេ

ផែនទីកំណត់តំបន់អាងទន្លេនៅក្នុងព្រះរាជាណាចក្រកម្ពុជា



**ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ ៩៨ អនក្រ.បក**
**ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងអាងទន្លេ**

## តារាងឈ្មោះនិងទំហំផ្ទៃអាងទន្លេនីមួយៗ

| លរ. | លេខកូដអាងទន្លេ | ឈ្មោះទន្លេ | ផ្ទៃអាងទន្លេ គម² |
|---|---|---|---|
| **១. តំបន់មាត់សមុទ្រ** | | | |
| ១ | ១ | ព្រែកកំពង់បាយ | ៣ ០១៨ |
| ២ | ២ | ព្រែកទឹកសាប | ១ ៥២៩ |
| ៣ | ៣ | ព្រែកស្រែអំបិល | ២ ៦៥៣ |
| ៤ | ៤ | ព្រែកអណ្តូងទឹក | ២ ៤៦០ |
| ៥ | ៥ | ព្រែកត្រពាំងរូង | ២ ៦១៥ |
| ៦ | ៦ | ព្រែកតាតៃ | ១ ៦១៩ |
| ៧ | ៧ | ព្រែកកោះប៉ោ | ៣ ១០៩ |
| ៨ | ៨ | ស្ទឹងមេទឹក | ១ ០៤៣ |
| | | **សរុប ១** | ១៨ ០៤៥ |
| **២. តំបន់ទន្លេបាសាក់** | | | |
| ៩ | ៩ | ស្ទឹងតន់ហាន់ | ១ ៧៦៥ |
| ១០ | ១០ | ស្ទឹងស្លាគូ | ២ ៤៨៥ |
| ១១ | ១១ | ស្ទឹងព្រែកត្នោត | ៧ ០៥៥ |
| | | **សរុប ២** | ១១ ៣០៥ |
| **៣. តំបន់ទន្លេសាប** | | | |
| ១២ | ១២ | ស្ទឹងក្រាំងពន្លៃ | ៣ ០៣៣ |
| ១៣ | ១៣ | ស្ទឹងបរិបូណ៌ | ៣ ០០៣ |
| ១៤ | ១៤ | ស្ទឹងបំណក់ | ១ ១១៦ |
| ១៥ | ១៥ | ស្ទឹងពោធិ៍សាត់ | ៥ ៩៦៤ |
| ១៦ | ១៦ | ស្ទឹងស្វាយដូនកែវ | ២ ២២៨ |
| ១៧ | ១៧ | ស្ទឹងមោងឫស្សី ស្ទឹងដូនទ្រី | ១ ៨៦៨ |
| ១៨ | ១៨ | ស្ទឹងសង្កែ | ៦ ០៥២ |
| ១៩ | ១៩ | ស្ទឹងមង្គលបុរី | ៥ ២៦៤ |
| ២០ | ២០ | ស្ទឹងសិរីសោភ័ណ | ៥ ៥៩៣ |
| ២១ | ២១ | ស្ទឹងស្រែង | ៩ ៩៣១ |
| ២២ | ២២ | ស្ទឹងសៀមរាប | ៣ ៦១៩ |

॥

| | | | |
|---|---|---|---|
| ២៣ | ២៣ | ស្ទឹងជីក្រែង | ២ ៧១៤ |
| ២៤ | ២៤ | ស្ទឹងស្លោង | ៤ ៣៥៧ |
| ២៥ | ២៥ | ស្ទឹងសែន | ១៦ ៣៤២ |
| ២៦ | ២៦ | ស្ទឹងជីនិត | ៨ ២៣៦ |
| ២៧ | ៣៩ | បឹងទន្លេសាប | ២ ៧៤៣ |
| | | **សរុប ៣** | ៨១ ៦៦៣ |
| **៤. តំបន់ទន្លេភាគឦសាន** | | | |
| ២៨ | ២៧ | ទន្លេសេកុង | ៥ ៥៦៤ |
| ២៩ | ២៨ | ទន្លេសេសាន | ៧ ៦២១ |
| ៣០ | ២៩ | ទន្លេស្រែពក | ១២ ៧៨០ |
| ៣១ | ៣០ | ព្រែកព្រះ | ២ ៣៩៩ |
| ៣២ | ៣១ | ព្រែកក្រៀង | ៣ ៣៣១ |
| ៣៣ | ៣២ | ព្រែកកាំពីរ | ១ ១៤២ |
| ៣៤ | ៣៣ | ព្រែកទេរ | ៤ ៣៦៣ |
| ៣៥ | ៣៤ | ព្រែកឆ្លូង | ៥ ៥៩៩ |
| | | **សរុប ៤** | ៤២ ៨០០ |
| **៥. តំបន់មេគង្គលើ(កម្ពុជា)** | | | |
| ៣៦ | ៣៥ | ដៃស្ទឹង ព្រែកទន្លេមេគង្គលើ (Mekong Riverine) | ១០ ៣៧៣ |
| | | **សរុប ៥** | ១០ ៣៧៣ |
| **៦. តំបន់ភាគអាគ្នេយ៍** | | | |
| ៣៧ | ៣៦ | ទន្លេវៃគោ | ៦ ៦១៨ |
| | | **សរុប ៦** | ៦ ៦១៨ |
| **៧. តំបន់ដីសណ្តមេគង្គក្រោម** | | | |
| ៣៨ | ៣៧ | មេគង្គដីសណ្តកម្ពុជា (Mekong Delta Cambodia) | ៨ ៧២៣ |
| ៣៩ | ៣៨ | តំបន់លិចទឹកទន្លេមេគង្គ ទន្លេសាប (ស្ពានត្រស់) | ១ ៥០៨ |
| | | **សរុប ៧** | ១០ ២៣១ |
| | | **សរុបរួម** | ១៨១ ០៣៥ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៤៤អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ សម្តេចក្រឡាហោម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១** ត្រូវបានបំពាក់មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ជូននាយនគរបាលជាតិ មន្ត្រីរាជការ លោក លោកស្រី និងសប្បុរសជន ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនរួមចំណែក អភិវឌ្ឍន៍មូលដ្ឋាន និងកសាងព្រះវិហារ សាលាបឋមសិក្សា ១ខ្នង៦បន្ទប់និងបង្គន់អនាម័យក្នុងវត្តអង្គសិរីស័ក្តយុំពាមមានជ័យស្រុកពាមរក៍ ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោមៈ

**ក. មេដាយ មុនីសារភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

| | | |
|---|---|---|
| ១- លោកវរសេនីយ៍ត្រី | ថោង វណ្ណឌី | អនុប្រធានប៉ុស្តិ៍ច្រកទ្វារព្រៃវល្លិ |
| ២- លោកវរសេនីយ៍ត្រី | ម៉ែន កល្យាណ | អនុប្រធានប៉ុស្តិ៍ច្រកទ្វារបាវិត |
| ៣- លោក | ហេង បូលីណា | សប្បុរសជន |
| ៤- លោក | សៀង ខុន | អាចារ្យវត្តអង្គសិរីស័ក្តិ |

**ខ. មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ**

| | | |
|---|---|---|
| ១- លោក | ឈឹម សារិន | គណៈកម្មការវត្តអង្គសិរីស័ក្តិ |
| ២- លោក | កែវ សារីម | គណៈកម្មការវត្តអង្គសិរីស័ក្តិ |
| ៣- លោក | អួន ឌី | គណៈកម្មការវត្តអង្គសិរីស័ក្តិ |

| | |
|---|---|
| ៤- លោក រស់ ស្រួន | គណៈកម្មការវត្តអង្គសិរីស័ក្តិ |
| ៥- ឧបាសិកា ងួន សឿយ | សប្បុរសជន |
| ៦- ឧបាសិកា ហួត គាម | សប្បុរសជន |
| ៧- លោក ទា សេងលាភ | សប្បុរសជន |
| ៨- លោកស្រី ហួត សៀងលាង | សប្បុរសជន |

**មាត្រា២** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្ត ព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ២
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៧៤៣...អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ សម្តេចក្រឡាហោម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូននាយនគរបាលជាតិ បន្ត្រីរាជការ លោក លោកស្រី និងសប្បុរសជន ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនរួមចំណែក អភិវឌ្ឍន៍មូលដ្ឋាន និងកសាងព្រះវិហារ សាលាបឋមសិក្សា ១ខ្នង៦បន្ទប់ និងបង្គន់អនាម័យក្នុងវត្តអង្គសិរីស័ក្ត ឃុំពាមមានជ័យ ស្រុកពាមរក៍ ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោមៈ

**ក. មេដាយ ការងារ ថ្នាក់ មាស**

| | |
|---|---|
| ១- លោក សុខ សាវ៉ាន | ក្រុមការងារស្រុកពាមរក៍ |
| ២- លោក សួស សារ៉ែន | ក្រុមការងារស្រុកពាមរក៍ |
| ៣- លោក ហុង ធី | នាយកសាលាបឋមសិក្សាបឹងក្អែក |
| ៤- លោក ចាន់ ទូច | គ្រូវិទ្យាល័យពាមពរក៍ |
| ៥- លោក ធឿន វី | គ្រូវិទ្យាល័យពាមពរក៍ |
| ៦- លោកស្រី គង់ ម៉ាលី | គ្រូវិទ្យាល័យពាមពរក៍ |
| ៧- លោកស្រី យោន សុភាព | គ្រូវិទ្យាល័យពាមពរក៍ |
| ៨- លោកអនុសេនីយ៍ត្រី ស៊ុំ វិទូមេត្តា | មន្ត្រីនគរបាលខេត្តបន្ទាយមានជ័យ |

**ខ. មេដាយ ការងារ ថ្នាក់ ប្រាក់**

| | |
|---|---|
| ១- លោកអនុសេនីយ៍ទោ ជា ហាក់ | មេប៉ុស្តិ៍ស្តីទីឃុំពាមមានជ័យ |
| ២- លោកស្រី ជា សោភ័ណ្ឌ | គ្រូបឋមបឹងក្អែក |
| ៣- លោកស្រី ថោង សារិន | គ្រូបឋមបឹងក្អែក |
| ៤- លោក ស៊ុម ធឿន | គ្រូបឋមបឹងក្អែក |
| ៥- លោកស្រី ញ៉ឹក យ៉ម | ក្រុមប្រឹក្សាឃុំពាមមានជ័យ |
| ៦- លោក ហាន វណ្ណា | លេខាធិការសាលាស្រុក |
| ៧- លោកស្រី ផន ផល្លីន | គ្រូមត្តេយ្យបឹងក្អែក |
| ៨- លោកស្រី ឆោម ស៊ីថាន | គ្រូមត្តេយ្យបឹងក្អែក |
| ៩- លោកស្រី ប៉ែន អយ | គ្រូមត្តេយ្យបឹងក្អែក |
| ១០- លោកស្រី កេម មនោ | គ្រូសាលាបឹងក្អែក |
| ១១- លោកស្រី ឈិត សុភី | គ្រូសាលាបឹងក្អែក |
| ១២- លោក ឈិត សំអាត | គ្រូសាលាបឹងក្អែក |
| ១៣- លោក យ៉ុន យ៉ាន់ | មេភូមិបឹងក្អែក |

**មាត្រា២** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្ត ព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៤៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោកស្រី **ហឿត ហ៊ីមុល្លី** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ ឱ្យកាន់មុខតំណែងជាអភិបាលរងនៃគណៈអភិបាលខេត្តព្រះសីហនុ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៤៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ចំនួន ០២រូប នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម៖

១-ឧត្តមសេនីយ៍ឯក **សេង សិរីបុត្រ** អត្តលេខ ០២២០៥ ពីអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ទៅជាអគ្គាធិការរង នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល។

២-ឧត្តមសេនីយ៍ត្រី **ម៉ិនប៉ា ម៉ារីលុច** អត្តលេខ ៥៥៥៥៦ ពីអនុប្រធាននាយកដ្ឋានអង្គរក្ស ទៅជាអគ្គាធិការរង នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៤៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៥/៣៥៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ទៅជាគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** តែងតាំងមន្ត្រីរាជការ ចំនួន ០៣ រូប ជាជំនួយការអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើប្រធាននាយកដ្ឋាន ដូចមានរាយនាមខាងក្រោម ៖

១- លោក **ខណ្ណរ៉ា ម៉ូរិទ្ធ** ជាជំនួយការអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ ប្រធាននាយកដ្ឋាន

២- លោក **ឡេង ម៉ុនដែន** ជាជំនួយការអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៣- លោក **អំ ម៉ាត** ជាជំនួយការអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ ប្រធាននាយកដ្ឋាន

**មាត្រា ២ .-** តែងតាំងមន្ត្រីរាជការ ចំនួន ០២ រូប ជាប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ដូចមានរាយនាមខាងក្រោម ៖

១- លោក **ទឹម សុវណ្ណា** ជាប្រធាននាយកដ្ឋានពិធីការ និងបដិសណ្ឋារកិច្ច

២- លោក **ទួន សុគន្ធ** ជាប្រធាននាយកដ្ឋានស្រាវជ្រាវប្រពៃណី ទំនៀមទម្លាប់ និងបោះពុម្ពផ្សាយ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាជិកថេរសភានៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.តត ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងធម្មការ និងសាសនា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១ ៖** តែងតាំងព្រះមហាវិមលធម្ម **ពិន សែម** ព្រះរាជាគណៈថ្នាក់ទោ គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា ជាសមាជិកថេរសភានៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីអង្គដូចមានក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ[illegible] ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបំពេញក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខណ្ឌ័មន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពេញក្របខ័ណ្ឌមន្ត្រីនគរបាលជាតិចំនួន៤៣កន្លែង (សែសិបបី) ដល់ក្រសួងមហាផ្ទៃ សម្រាប់តម្រូវការចាំបាច់នៃការងារសន្តិសុខជាតិ ថែរក្សាសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ។

**មាត្រា២ :** ក្របខ័ណ្ឌបំពេញថ្មីនេះ ត្រូវបានទទួលប្រាក់បៀវត្សរ៍ និងរបបឧបត្ថម្ភផ្សេងៗ របស់មន្ត្រីនគរបាលជាតិ ចាប់ពីខែតុលា ឆ្នាំ២០១៥ តទៅ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៤៩ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ពៅ ពិសិដ្ឋ** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ឱ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្តសៀមរាប។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥០ អនក្រ.តត

# អនុក្រឹត្យ

## ស្ដីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្ដីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **គិម ខណ្ណៈ** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ ឱ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលស្រុកសង្កែ ខេត្តបាត់ដំបង។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៧៤១ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ដាក់មន្ត្រីរាជការ ចំនួន ០៥ រូប របស់ក្រសួងធនធានទឹក និងឧតុនិយម **ឱ្យចូលនិវត្តន៍**ក្នុងឋានន្តរស័ក្តិ វរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១- លោក **ស៊ឹម សុផល** | វរមន្ត្រី ថ្នាក់លេខ **២** ចូលនិវត្តន៍ថ្ងៃទី **០១ ខែ ឧសភា ឆ្នាំ ២០១៥** |
| ២- លោក **ម៉េ ចេង** | វរមន្ត្រី ថ្នាក់លេខ ១ ចូលនិវត្តន៍ថ្ងៃទី **០១ ខែ កុម្ភៈ ឆ្នាំ ២០១៥** |
| ៣- លោក **ភួយ សុខារិទ្ធ** | វរមន្ត្រី ថ្នាក់លេខ ៤ ចូលនិវត្តន៍ថ្ងៃទី **០១ ខែ មិថុនា ឆ្នាំ ២០១៥** |
| ៤- លោក **ម៉ី ម៊ុនថៃ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ **២** ចូលនិវត្តន៍ថ្ងៃទី **០១ ខែ មករា ឆ្នាំ ២០១៦** |
| ៥- លោក **ចូម សុខច័ន្ទ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ ចូលនិវត្តន៍ថ្ងៃទី **០១ ខែ មករា ឆ្នាំ ២០១៦** |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧០៥៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការលុបឈ្មោះនាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១.-**

លុបឈ្មោះលោកវរសេនីយ៍ឯក **រ័ត្ន គឹមឿន** អត្តលេខ ០១២០០៤ ចេញពីក្របខ័ណ្ឌកងហោះដឹកជញ្ជូនប្រតិភូជាន់ខ្ពស់ នៃទីស្តីការគណៈរដ្ឋមន្ត្រី ដោយមូលហេតុសាមីខ្លួនទទួលមរណភាព។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៥៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃអភិបាលនៃគណៈអភិបាលខេត្តកណ្តាល

**សម្រេច**

**មាត្រា ១.-** បំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ** ចំនួន ០១គ្រឿង ប្រគេន ព្រះតេជគុណជោតិធម្មោ **សឿន ថារ័ត្ន** ដែលបានបរិច្ចាគបច្ច័យ ចំនួន ៣៥.០០០ដុល្លារអាមេរិក ចូលរួមជួយកសាងព្រះវិហារ នៅវត្តកែវមុនីវ័ន្ត ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល កន្លងមក។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកក្កដា, ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៥៤ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃអភិបាលនៃគណៈអភិបាលខេត្តកណ្តាល

### សម្រេច

**មាត្រា ១.-** បំពាក់ មេដាយមាសស្ថាបនាជាតិ ចំនួន ០៥គ្រឿង ជូនសប្បុរសជន ចំនួន ០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមកសាងព្រះវិហារ នៅវត្តកែវមុនីវ័ន្ត ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | អ្នកស្រី | លឹម សុវណ្ណបុប្ផា | សប្បុរសជននៅរាជធានីភ្នំពេញ ថវិកា ១៧.២០០ ដុល្លារ |
| ២- | អ្នកស្រី | សើ ចំរើន | សប្បុរសជននៅឃុំសំបួរមាស ថវិកា ១៦.៣០០ ដុល្លារ |
| ៣- | ឧបាសក | ម៉ៀច ធ្រាក់ | សប្បុរសជននៅឃុំសំបួរមាស ថវិកា ១៤.៥០០ ដុល្លារ |
| ៤- | ឧបាសក | គង់ សំណាង | សប្បុរសជននៅឃុំសំបួរមាស ថវិកា ១៣.០០០ ដុល្លារ |
| ៥- | ឧបាសក | ស៊ុន ងីម | សប្បុរសជននៅឃុំសំបួរមាស ថវិកា ១២.៥០០ ដុល្លារ |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..៧៥៥..អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

**សម្រេច**

**មាត្រា១.**_បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនបុគ្គលិកអង្គភាពស៊ីម៉ាក់ ចំនួន០២រូប ដែលមានស្នាដៃល្អក្នុងការជួយសាងសង់សាលារៀន ផ្លូវគ្រួសក្រហម នៅមណ្ឌលអភិវឌ្ឍន៍ស៊ីម៉ាក់មរតកតេជោ ឃុំឆ្នាល់មាន់ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កន្លែងម៉ក ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១-អ្នកស្រី **និត្យ ជាវី** | នាយកប្រតិបត្តិអង្គការ OEC |
| ២-លោក **ម៉ោញ សម្បត្តិ** | អនុប្រធានអង្គការ Good Earth Japan |

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

## សម្រេច

**មាត្រា១.** បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនបុគ្គលិកអង្គភាពស៊ីម៉ាក់ ចំនួន៥០រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ**

| | | | |
|---|---|---|---|
| ១-លោក | ចែម | សម្បត្តិ | ប្រធានមណ្ឌលអភិវឌ្ឍន៍សហគមន៍ |
| ២-លោក | នី | ឌុច | នាយផ្នែកវិស្វកម្ម |
| ៣-លោក | ប៉ែន | សុរ្យចិន្តា | ប្រធានក្រុមវិស្វកម្ម |
| ៤-លោក | ឌុច | យ៉ុន | អ្នកបញ្ជាគ្រឿងចក្រ |
| ៥-លោក | ហាក់ | ម៉ិនវណ្ណា | ប្រធានការដ្ឋាន |
| ៦-លោក | សាន | ញិប | ប្រធានក្រុមអ្នកដោះមីន |
| ៧-លោក | សុត | កុសល | ជំនួយការចលនូបត្ថម្ភ |
| ៨-លោក | ឌុយ | សាន | អ្នកបញ្ជាគ្រឿងចក្រ |
| ៩-លោក | ម៉ៅ | សឿន | សមាជិក BAT |
| ១០-លោក | គួន | រម្សា | ប្រធានកងចល័ត |

| | | | |
|---|---|---|---|
| ១១-លោក | ទុំ | ចំនួសេរី | ប្រធានផានក្រុម BCT |
| ១២-លោក | មិត្ត | សារិទ្ធ | ប្រធានក្រុម TSC |
| ១៣-លោក | យ៉ាន់ | សុខុម | ប្រធានកងចល័ត |
| ១៤-លោក | អៀម | រដ្ឋា | ប្រធានកងចល័ត |
| ១៥-លោក | អ៊ឹម | រ៉ាមិច | ប្រធានកងចល័ត |
| ១៦-លោក | ប៉ែន | វណ្ណី | ប្រធានកងចល័ត |
| ១៧-លោក | សំ | សាវុធ | ប្រធានកងចល័ត |
| ១៨-លោក | ញ៉ឹង | សារិក | ប្រធានកងចល័ត |
| ១៩-លោក | ព្រែម | ញួន | ប្រធានកងចល័ត |
| ២០-លោក | ហាវ | វ៉ាន់ | ប្រធានកងចល័ត |
| ២១-លោក | ពេជ្រ | និន | ប្រធានកងចល័ត |
| ២២-លោក | ឡាំ | ណារ៉ា | ប្រធានក្រុម BC |
| ២៣-លោក | គុណ | ពៅ | ប្រធានក្រុម BC |
| ២៤-លោក | សួស | ពៅ | ប្រធានក្រុម BC |
| ២៥-លោក | ឌិត | ប៊ុនសែន | ប្រធានក្រុម BC |

**ខ-មេដាយប្រាក់ការងារ**

| | | | |
|---|---|---|---|
| ១-លោក | ហេង | មួយ | ប្រធានក្រុម EOD |
| ២-លោក | ចាន់ | សាវ៉េត | ប្រធានក្រុម |
| ៣-លោក | ឡុង | សុភាព | ប្រធានក្រុម BAC |
| ៤-លោក | កៅ | ណារី | សមាជិក BAC |
| ៥-លោក | ប៉ែន | សុវណ្ណា | សមាជិក BAC |
| ៦-លោក | ឡុង | សុវណ្ណា | ប្រធានក្រុម |
| ៧-លោក | យន | ចន្ថា | ប្រធានក្រុម |
| ៨-លោក | ជា | វិចិត្រ | ប្រធានក្រុម |
| ៩-លោក | សួរ | វុត្ថា | ប្រធានកង |
| ១០-លោក | ឈឹម | សុផារិទ្ធ | ប្រធានក្រុមដោះមីន |
| ១១-លោក | ស្រី | ប៊ុនរ៉េត | ប្រធានក្រុមដោះមីន |
| ១២-លោក | ទួន | សំអឿន | ប្រធានក្រុមដោះមីន |
| ១៣-លោកស្រី | គិន | កញ្ញា | សមាជិក IED |
| ១៤-លោក | ពៅ | សុខាណា | គ្រូបច្ចេកទេស |
| ១៥-លោក | អ៊ុង | ឃុន | នាយផ្នែកត្រួតពិនិត្យផ្នែកបោសសំអាតយុទ្ធភណ្ឌមិនទាន់ផ្ទុះ |
| ១៦-លោក | សេង | យឹប | ប្រធានក្រុម BAV |
| ១៧-លោក | ប៊ួយ | គីមលៀង | ប្រធានក្រុម BAC |
| ១៨-លោកស្រី | តែ | សុខាលី | ប្រធានហិរញ្ញវត្ថុ (MAG) |
| ១៩-លោក | តូច | សារិន | អ្នកដោះមីន (MAG) |
| ២០-លោក | អ៊ុន | សារ៉ាត់ | ប្រធានសម្របសម្រួលផ្នែកធានាគុណភាពសកម្មភាពមីន(MAG) |

| | | | |
|---|---|---|---|
| ២១-លោកស្រី | ទៀន | សុណាន់ | ប្រធានក្រុម (MAG) |
| ២២-លោកស្រី | ជាន | សីយ | អ្នកកាន់សុនខក្រុម SLD02 (DU2) |
| ២៣-លោក | យឿន | យ៉ាន | អ្នកកាន់សុនខក្រុម SLD03 (DU2) |
| ២៤-លោក | ឡៅ | ជីប | អ្នកកាន់សុនខក្រុម SLD09 (DU2) |
| ២៥-លោកស្រី | ជីម | ស្រីម៉ៅ | ប្រធានក្រុម SLD12 (DU2) |

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៥៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**មាត្រា១.**_បំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៦រូប ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត និងបរិច្ចាគថវិកា ជួយស្ថាបនាផ្លូវបេតុង កុដិ បង្គោលភ្លើង និងសមិទ្ធផលនានា នៅក្នុងវត្តគិរីធម្មបទខ្នាកូនថ្មី សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយប្រាក់ស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-លោក | **ឈួន ហាន និង ភរិយា** | សប្បុរសជននៅក្រុងសិរីសោភ័ណ | ថវិកាចំនួន ៥.៥០០ ដុល្លារ |
| ២-លោក | **ឆៀ ហ៊ុយម៉េង និង ភរិយា** | សប្បុរសជននៅក្រុងសិរីសោភ័ណ | ថវិកាចំនួន ៥.៣០០ ដុល្លារ |
| ៣-លោក | **លី វ៉ាឈីត និង ភរិយា** | សប្បុរសជននៅក្រុងសិរីសោភ័ណ | ថវិកាចំនួន ៥.២០០ ដុល្លារ |
| ៤-លោក | **ឈឿន បុត្រា និង ភរិយា** | សប្បុរសជននៅក្រុងសិរីសោភ័ណ | ថវិកាចំនួន ៥.២០០ ដុល្លារ |

**ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-លោក | **ឈិត ភក្តី និង ភរិយា** | សប្បុរសជននៅក្រុងសិរីសោភ័ណ | ថវិកាចំនួន ២.៥០០ ដុល្លារ |
| ២-លោក | **រុន សារឿន និង ភរិយា** | សប្បុរសជននៅក្រុងសិរីសោភ័ណ | ថវិកាចំនួន ២.៥០០ ដុល្លារ |

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ   សាសនា   ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..[illegible]

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**មាត្រា១.**.បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេនព្រះតេជគុណ **សំ ទ៉ាន់ថា** ព្រះគ្រូចៅអធិការវត្ត **គិរីធម្មបទខ្លាកូនថ្មី** ដែលបានខិតខំអស់ពីព្រះទ័យ ចលនាពុទ្ធបរិស័ទ ជួយស្ថាបនាផ្លូវបេតុង កុដិ បង្គោលភ្លើង និងសមិទ្ធផលនានា នៅក្នុង**វត្តគិរីធម្មបទខ្លាកូនថ្មី** សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

**មាត្រា២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:....៥៩.សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការកែសម្រួលសមាជិកក្រុមការងារ**

**ថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី**

**នយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានផ្លាស់ប្តូរសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅរាជធានី-ខេត្ត ដូចខាងក្រោម៖

១-លោកជំទាវ **ស៊ើង សរសុចិន្តា** រដ្ឋលេខាធិការក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ពីសមាជិកក្រុមការងារខេត្តស្វាយរៀង មកជាសមាជិកក្រុមការងាររាជធានីភ្នំពេញ។

២-ឯកឧត្តម **ស៊ិន ខ័ណ្ឌី** អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន ពីសមាជិកក្រុមការងារខេត្តកំពង់ស្ពឺ មកជាសមាជិកក្រុមការងារខេត្តកណ្តាល។

**ប្រការ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលរាជធានី-ខេត្ត និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ..៥៩..សរសរ**

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតក្រុមការងារបច្ចេកទេស**

**នៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ១៧២ សសរ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេស នៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ សម្រាប់ជំរុញការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ដែលមានសមាសភាព ដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្តម **ស៊ុំ សន្និសិទ្ធ** | អគ្គលេខាធិការ ធនាគារជាតិនៃកម្ពុជា | ប្រធាន |
| ២- ឯកឧត្តម **ម៉ី វ៉ាន់** | អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- លោកជំទាវ **ជា សិរី** | អគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- ឯកឧត្តម **គិម វ៉ាដា** | អគ្គនាយកត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៥- លោកជំទាវ **សាយ សំអាត** | អគ្គលេខាធិការ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | សមាជិក |
| ៦- ឯកឧត្តម **សុខ ដារ៉ា** | អគ្គនាយករង គណៈកម្មការមូលបត្រកម្ពុជា | សមាជិក |
| ៧- លោក **ជូ ចណ្ណៈ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- លោក **ម៉ូ ចំន្ទតីរ្យ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩- លោក **រស់ តីរុណា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០- លោក **ទេព ម៉ុន្ថា** | អគ្គនាយករងរដ្ឋបាល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១១- លោក **ថៃ សភា** | អគ្គលេខាធិការរង ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១២- លោក **វ័ត្ថ សុវណ្ណនរៈ** | អគ្គនាយករងត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១៣- លោក **គីមធី ភោមលី** | អគ្គនាយករងបច្ចេកទេស ធនាគារជាតិនៃកម្ពុជា | សមាជិក |

| | | |
|---|---|---|
| ១៤- លោក **ខែត សុវណ្ណារិទ្ធ** | ប្រធាននាយកដ្ឋានត្រួតពិនិត្យលើឯកសារ ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១៥- លោក **ឃូ ទុរស្មី** | ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១៦- លោក **អ៊ុក សារ៉ាត** | ប្រធាននាយកដ្ឋានប្រព័ន្ធទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១៧- លោក **ណើ សាគល** | ប្រធាននាយកដ្ឋានទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៨- លោក **នេខ ពិសិដ្ឋ** | ប្រធាននាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្រទាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៩- លោក **ឆាយ រតនៈ** | ប្រធាននាយកដ្ឋានធានារ៉ាប់រង និងសោធន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២០- លោក **ស៊ឹម សុខខេង** | ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២១- លោក **ឡាយ ត្តក** | ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២២- លោក **សៅ ឡែន** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ២៣- លោក **ស្វ៊ុ ម៉ូលែន** | ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ គណៈកម្មការមូលបត្រកម្ពុជា | សមាជិក |
| ២៤- លោក **ទិន តក្តី** | ប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ គណៈកម្មការមូលបត្រកម្ពុជា | សមាជិក |
| ២៥- លោកស្រី **សុខ សុគន្ធជីវី** | ប្រធានស្តីទី នាយកដ្ឋានកិច្ចការគតិយុត្ត គណៈកម្មការមូលបត្រកម្ពុជា | សមាជិក |

| | | |
|---|---|---|
| ២៦- លោកស្រី **នាន មុនី** | ប្រធានស្តីទី នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយ លក់មូលបត្រ គណៈកម្មការមូលបត្រកម្ពុជា | សមាជិក |
| ២៧- លោកស្រី **ស៊ុន ណាលី** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការនិង គ្រប់គ្រងបំណុល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២៨- លោក **ម៉ូ ថារិន** | លេខាធិការរង ក្រុមប្រឹក្សាជាតិគណនេយ្យ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២៩- លោក **ម៉េង ចាន់ណារិទ្ធ** | ប្រធានការិយាល័យគោលនយោបាយរូបិយវត្ថុ ធនាគារជាតិនៃកម្ពុជា | សមាជិក និងលេខាធិការ ។ |

**ប្រការ ២.-**

ក្រុមការងារបច្ចេកទេស នៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ **(គ.អ.ហ)** មានភារកិច្ចដូចតទៅ ÷

- បំពេញការងារតាមការណែនាំរបស់គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- ធ្វើការងារជាមួយក្រុមជំនួយបច្ចេកទេស ដើម្បីជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងក្នុងកិច្ចព្រមព្រៀងឥណទាន ឱ្យទទួលបានជោគជ័យ
- ជំនួយការឱ្យ **គ.អ.ហ** ក្នុងការតាមដាន និងត្រួតពិនិត្យនូវការអនុវត្តការងារប្រចាំថ្ងៃរបស់ក្រុមប្រតិបត្តិការប្រចាំសាមីស្ថាប័ននីមួយៗ
- ពិនិត្យ និងតាមដានការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១ - ២០២០ របស់រាជរដ្ឋាភិបាល
- រៀបចំ និងធ្វើបច្ចុប្បន្នកម្ម "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ" តាមការចាំបាច់
- សម្របសម្រួលឱ្យមានការឯកភាពរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា លើរាល់បញ្ហាដែលពាក់ព័ន្ធទៅនឹង ÷
    - ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ
    - ការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង
    - ការត្រួតពិនិត្យលើការអនុវត្តការងារគ្រប់គ្រងហិរញ្ញវត្ថុដែលកំពុងប្រើប្រាស់
- ធ្វើរបាយការណ៍ជាទៀងទាត់ជូន **គ.អ.ហ** អំពីការវិវត្តនៃផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ។

**ប្រការ ៣.-**

ក្រុមការងារបច្ចេកទេសនេះ ត្រូវរៀបចំប្រជុំយ៉ាងតិច ៣ដង ក្នុងមួយឆ្នាំ និង/ឬ តាមការចាំបាច់ និងត្រូវរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពអភិវឌ្ឍវិស័យហិរញ្ញវត្ថុជូន **គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ** ។

តាមការអញ្ជើញរបស់ប្រធាន អនុប្រធាននិងសមាជិក ត្រូវចូលរួមប្រជុំ ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំក្នុងករណីអវត្តមានឬមានធុរៈ ។

**ប្រការ ៤.-**

ក្រុមការងារបច្ចេកទេសនេះ មានសិទ្ធិអញ្ជើញមន្ត្រីផ្សេងៗទៀតនៃក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធចូលរួមការងារបាន ។

ក្រុមការងារបច្ចេកទេសនេះ មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំតាមការចាំបាច់ ។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០៧០៣.....សហវ....

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការតែងតាំងវង្វេឲយ្យករបុរេប្រទាន របស់ក្រសួងអប់រំ យុវជន និងកីឡា នៅនាយកដ្ឋានគម្រូងវិស័យជីវៈ

**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

-បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

-បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី ១៥ខែមករាឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ

-បានឃើញប្រកាសអន្តរក្រសួងលេខ ១៦២ អយក.ប្រក ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា

-យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**ប្រការ១:**

ត្រូវបានតែងតាំងមន្ត្រីរាជការនៃក្រសួងអប់រំ យុវជន និងកីឡាដូចខាងក្រោម:

**១.លោក ឡេង ស៊ីវណ្ណជុល្លា** ឋានៈជាអនុប្រធានការិយាល័យបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យទទួលបន្ទុកការងារជារជ្ជទេយ្យករបុរេប្រទាន

**២.លោក សុគន្ធី រតនៈ** ឋានៈជាមន្ត្រីការិយាល័យរដ្ឋបាល ឱ្យទទួលបន្ទុកការងារជារជ្ជទេយ្យករបុរេប្រទានរង

**ប្រការ២:**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៣:**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ និង ប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**កន្លែងទទួល:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-ដូចប្រការ៣
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
លេខ ៧២១ សហវ.ប្រក

# ប្រកាស
# ស្ដីពី
# ការបង្កើតនិងតែងតាំងក្រុមលទ្ធកម្ម
# របស់គណៈកម្មការមូលបត្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកអ/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦/ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ដីពីនីតិវិធី នៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92 Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ. បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសារធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំនិងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិការកម្មវិធី
- បានឃើញប្រកាសលេខ ២៥៦ សហវ. ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអគ្គនាយក នៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញប្រកាសលេខ ២៤៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាព-ថវិកា
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មការមូលបត្រកម្ពុជា

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតនិងតែងតាំងក្រុមលទ្ធកម្មរបស់គណៈកម្មការមូលបត្រកម្ពុជាដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តម **ស៊ូ សុជាតិ** | អគ្គនាយក នៃគណៈកម្មការមូលបត្រកម្ពុជា | ជាប្រធាន |
| ២. ឯកឧត្តម **ឈុន សម្បត្តិ** | អគ្គនាយករង នៃគណៈកម្មការមូលបត្រកម្ពុជា | ជាអនុប្រធាន |
| ៣. លោក **ទីឹង ចន្ថា** | ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៤. លោក **លុយ ហុក** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៥. លោកស្រី **គង់ ស៊ីលីយ៉ា** | ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក | ជាសមាជិក។ |

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.–**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ......៨២៩......សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការកែសម្រួលប្រការ ៤ ប្រការ ៥ ប្រការ ១៤ ប្រការ ១៦ និងប្រការ ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសសកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ១៥៨៩ សហវ.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីវិធាននិងនីតិវិធីអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- ប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមការចំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការមួយ.-**

ប្រការ៤ ប្រការ៥ ប្រការ ១៤ ប្រការ ១៦ និងប្រការ ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រូវបានកែសម្រួលដូចខាងក្រោម÷

**ប្រការ៤ថ្មី.-**

រជ្ជទេយ្យបុរេប្រទានគឺជាចំណាយលើដំណើរការរដ្ឋបាល និងចំណាយដែលមានលក្ខណៈជាប្រចាំ ចាំបាច់ បន្ទាន់ និងមិនអាចរង់ចាំការបោះផ្សាយអាណត្តិបើកប្រាក់តាមនីតិវិធីធម្មតាបាន។ មុខសញ្ញាចំណាយតាមរជ្ជទេយ្យបុរេប្រទានរួមមាន÷

- ចំណាយចាំបាច់ជាប្រចាំ សម្រាប់ការងាររដ្ឋបាល មានជាអាទិ៍ ការទិញសម្ភារៈ និងការជួសជុល
- ចំណាយសម្រាប់សង្គ្រោះជាបន្ទាន់និងពិសេស
- ចំណាយសម្រាប់ប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស
- ចំណាយសម្រាប់លាភការរបស់បុគ្គលិក
- ចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា
- ចំណាយសម្រាប់គាំទ្រដល់ការអនុវត្តសកម្មភាពនៃថវិកាកម្មវិធី។

**ប្រការ៥ថ្មី.-**

*ក. សម្រាប់ថវិកាមិនមែនកម្មវិធី*

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានសម្រាប់ថវិកាមិនមែនកម្មវិធី ត្រូវបង្កើតឡើងដោយជ្រើសរើសយកមាតិកាចំណាយតាមគណនីនិងអនុគណនីនៃជំពូក៦០ "ការទិញ", ជំពូក៦១ "សេវាកម្ម", ជំពូក៦២ "អត្ថប្រយោជន៍សង្គម", ជំពូក៦៤ "បន្ទុកបុគ្គលិក", និងជំពូក៦៥ "ឧបត្ថម្ភកធន" ដែលជាចំណាយចាំបាច់សម្រាប់កិច្ចដំណើរការរដ្ឋបាលដោយគិតក្នុងកម្រិតអតិបរមាមិនឱ្យលើសពី ៣០ភាគរយ នៃឥណទានតាមជំពូកដែលជ្រើសរើស។

ក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ទំហំឥណទានចំណាយដែលជ្រើសរើសពីគណនីនិងអនុគណនីពុំតម្រូវឱ្យកម្រិតចំនួន ៣០ ភាគរយ ស្មើៗគ្នានៃឥណទានសរុបតាមគណនីនិងអនុគណនីនីមួយៗនោះទេ គឺអាចតិចឬ ច្រើនទៅតាមតម្រូវការចាំបាច់នៃការចំណាយ ប៉ុន្តែឥណទានចំណាយសរុបតាមជំពូកនីមួយៗ មិនត្រូវលើសពី ៣០ភាគរយ នៃឥណទានតាមជំពូកដែលបានជ្រើសរើសមកបង្កើតរជ្ជទេយ្យបុរេប្រទាននោះឡើយ។

*ខ. សម្រាប់ថវិកាកម្មវិធី*

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធី ត្រូវបង្កើតឡើងដោយជ្រើសរើសយកមាតិកាចំណាយតាមគណនីនិងអនុគណនីនៃជំពូក៦០ "ការទិញ", ជំពូក៦១ "សេវាកម្ម", ជំពូក៦២ "អត្ថប្រយោជន៍សង្គម", ជំពូក៦៤"បន្ទុកបុគ្គលិក", និងជំពូក៦៥"ឧបត្ថម្ភធន" ដែលជាចំណាយសម្រាប់កិច្ចដំណើរការរដ្ឋបាល និងជាចំណាយដែលមានលក្ខណៈប្រចាំ ចាំបាច់ បន្ទាន់សម្រាប់អនុវត្តសកម្មភាពនៃថវិកាកម្មវិធី អាចអនុវត្ត១០០ភាគរយនៃឥណទានតាមគណនីនិងអនុគណនីនីមួយៗដែលជ្រើសរើសដោយដកតែឥណទាន សម្រាប់ចំណាយតាមនីតិវិធីទូទាត់ត្រង់ មានជាអាទិ៍÷ ចំណាយចាំបាច់ដែលតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ចំណាយលើប្រាក់បៀវត្ស។ល។

ដោយឡែក ឥណទានថវិកាសម្រាប់បេសកកម្មក្នុងនិងក្រៅប្រទេស ឥណទានថវិកាសម្រាប់ការរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា អាចអនុវត្តតាមរជ្ជទេយ្យបុរេប្រទាន ១០០ភាគរយ។

ក្នុងករណីចាំបាច់ ក្រសួង ស្ថាប័នថវិកាកម្មវិធី អាចស្នើសុំធ្វើការកែសម្រួលតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានឡើងវិញតាមតម្រូវការចំណាយជាក់ស្តែង ដោយត្រូវភ្ជាប់មកជាមួយនូវលិខិតស្នើសុំកែសម្រួល និងសេចក្តីព្រាងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានថ្មី។

គំរូតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធីត្រូវបានកំណត់ជាឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ១៥ថ្មី.-**

ចំពោះការដកសាច់ប្រាក់រជ្ជទេយ្យបុរេប្រទាននៅជុំបង្វិលដំបូង រជ្ជទេយ្យករបុរេប្រទានអាចស្នើសុំដកប្រាក់រជ្ជទេយ្យបុរេប្រទានស្មើ ឬ តិចជាងចំនួនទឹកប្រាក់នៃជុំបង្វិល តាមរយៈប័ណ្ណដកឥណទានដែលមានចុះហត្ថលេខាត្រឹមត្រូវដោយពុំចាំបាច់បញ្ជាក់អំពីមុខសញ្ញាចំណាយ ពុំចាំបាច់មានការបញ្ជាពីអាណាប័ក ឬ ទិដ្ឋាការរបស់អភិបាលហិរញ្ញវត្ថុ។

ក្នុងករណីការបង្កើតរជ្ជទេយ្យបុរេប្រទាននាដើមឆ្នាំថវិកាមានភាពយឺតយ៉ាវ រជ្ជទេយ្យករបុរេប្រទានអាចស្នើសុំដកប្រាក់រជ្ជទេយ្យបុរេប្រទានដំបូងស្មើនឹងចំនួនទឹកប្រាក់មួយជុំបង្វិលនៃតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានឆ្នាំមុន ឬ នៃសេចក្តីព្រាងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានក្នុងឆ្នាំអនុវត្តថវិកា។ ដោយឡែក ក្រសួង ស្ថាប័នថវិកាកម្មវិធី ត្រូវរៀបចំបង្កើតរជ្ជទេយ្យបុរេប្រទាននិងប្រគល់ជូនគណនេយ្យករសាធារណៈ និងអភិបាលហិរញ្ញវត្ថុ នូវប្រកាសអន្តរក្រសួង ឬ ដីកាស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទាន ដោយភ្ជាប់មកជាមួយនូវតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ១៦ថ្មី.-**

រាល់ប័ណ្ណចំណាយ ត្រូវភ្ជាប់មកជាមួយនូវគោលការណ៍ចំណាយ វិក្កយបត្រ ឬ សក្ខីបត្រចំណាយ ដែលរជ្ជទេយ្យករបុរេប្រទានបានធ្វើការទូទាត់ ដោយមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក ឬ ពីអ្នកដែលទទួលបានការផ្ទេរសិទ្ធិពីអាណាប័ក។

អនុញ្ញាតឱ្យរជ្ជទេយ្យករបុរេប្រទានយក វិក្កយបត្រ ឬ សក្ខីបត្រចំណាយដែលបានចុះកាលបរិច្ឆេទរយៈពេលយ៉ាងយូរ ៣០ថ្ងៃ មុនពេលមានសាច់ប្រាក់ក្នុងបេឡារជ្ជទេយ្យបុរេប្រទាន មកធ្វើជាលិខិតយុត្តិការចំណាយដើម្បីបោះផ្សាយអាណត្តិនិយ័តកម្ម ប៉ុន្តែប័ណ្ណចំណាយត្រូវចុះកាលបរិច្ឆេទ នៅក្រោយពេលបានបំពេញបេឡាសាច់ប្រាក់រជ្ជទេយ្យបុរេប្រទាន។ ក្នុងករណីវិក្កយបត្រ ឬ សក្ខីបត្រចំណាយបានចុះកាលបរិច្ឆេទលើសពី៣០ថ្ងៃ មុនពេលមានសាច់ប្រាក់ក្នុងបេឡារជ្ជទេយ្យបុរេប្រទាន រជ្ជទេយ្យករបុរេប្រទានត្រូវរាយការណ៍ជូនអាណាប័ក ឬ អាណាប័កផ្ទេរសិទ្ធិ ដើម្បីស្នើសុំគោលការណ៍ដោយឡែកពីអភិបាលហិរញ្ញវត្ថុ និងគណនេយ្យករសាធារណៈ។

**ប្រការ១៧ថ្មី.-**

ចំនួនទឹកប្រាក់សម្រាប់មួយប័ណ្ណចំណាយ ត្រូវបានកំណត់ដូចខាងក្រោម÷

- ១ ៥០០ ០០០(មួយលានប្រាំរយពាន់) រៀល ជាអតិបរមា សម្រាប់ថវិកាមិនមែនកម្មវិធី លើកលែងតែចំណាយពិសេសរបស់រាជរដ្ឋាភិបាលនិងចំណាយដែលមានរបបកំណត់ច្បាស់លាស់ ដែលត្រូវទូទាត់តាមការចំណាយជាក់ស្តែង ដោយមិនកំណត់ចំនួនទឹកប្រាក់ក្នុងមួយប័ណ្ណចំណាយ
- ៥ ០០០ ០០០(ប្រាំលាន) រៀល ជាអតិបរមា សម្រាប់ថវិកាកម្មវិធី លើកលែងតែចំណាយពិសេសរបស់រាជរដ្ឋាភិបាល, ចំណាយលើប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេស, ចំណាយរៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា, និងចំណាយដែលមានរបបកំណត់ច្បាស់លាស់ ដែលត្រូវទូទាត់តាមការចំណាយជាក់ស្តែង ដោយមិនកំណត់ចំនួនទឹកប្រាក់ក្នុងមួយប័ណ្ណចំណាយ។

រដ្ឋទេយ្យករបុរេប្រទាន ឬ រដ្ឋទេយ្យករបុរេប្រទានរង ត្រូវជៀសវាងដាច់ខាតនូវការបំបែកប័ណ្ណចំណាយទៅតាមទីកន្លែង ឬ គោលដៅចំណាយ ពេលវេលា ទឹកប្រាក់ចំណាយ និងសមាសធាតុនៃមុខសញ្ញាចំណាយ ក្នុងគោលបំណងគេចវេសការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។

**ប្រការពីរ.-**

ប្រកាសនេះ ត្រូវមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ លើកលែងតែផ្នែកឥណទានថវិកាសម្រាប់បេសកកម្មក្រៅប្រទេស ដូចមានចែងក្នុងប្រការ៥ថ្មី នឹងមានអនុភាពអនុវត្តចាប់ពីដើមឆ្នាំ២០១៦ តទៅ។

ប្រការផ្សេងទៀតនៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រូវបន្តអានុភាពអនុវត្ត។

**ប្រការបី.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការបួន.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- ដូចប្រការបួន
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៦៩៤ ឧស.ក.ស.ក.ច.០៤

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ របស់ក្រុមហ៊ុន តៃអ៊ីហ្ស៊ី អ៊ិនធើណេសិនណល ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន តៃអ៊ីហ្ស៊ី អ៊ិនធើណេសិនណល (TAIEASY INTERNATIONAL CO., LTD.) តំណាងដោយ លោកស្រី ចាំង យ៉េនហ្វាន បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៥ ភូមិទទឹង ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រកាត់ដេរសម្លៀកបំពាក់ តៃអុីហ្វុី អុិនធើណេសិនណល"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាប់ហើសអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសលេខ ០៦៩ ឧរ៉ែ.កឧ.ប្រក. ចុះ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន តៃអ៊ីហ្ស៊ី អ៊ិនធើណេសិនណល ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តពោធិ៍សាត់ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន:**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -សាលាខេត្តពោធិ៍សាត់
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ១៩៧...ឧស.ករ.ប/ពរ.០៥

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតសាខារោងចក្រ របស់ក្រុមហ៊ុន ជុងហ្វៃ នីតវៀរ អេហ្វធីវ៉ាយ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ជុងហ្វៃ នីតវៀរ អេហ្វធីវ៉ាយ (CHUNG FAI KNITWEAR FTY., LTD.) តំណាងដោយ លោក SUN KIM HUNG បង្កើតសាខារោងចក្រ ផលិតអាវចាក់ ដែលមានទីតាំងស្ថិតនៅភូមិស្វាយកណ្តាល ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១-សម្លៀកបំពាក់ (កាត់ដេរ) | ១៤១០ |
| ២-សម្លៀកបំពាក់ (ចាក់) | ១៤៣០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រផលិតអាវចាក់ សាខាក្រុមហ៊ុន ជុងហ្វៃ នីតវៀរ អេហ្វជីវ៉ាយ អិលធីឌី"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ នីងស័ប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសលេខ ៥៦២ ឧរថ.កឧ.ប្រក. និងវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រលេខ ០៦៣/១៣ ឧរថ.កឧ.ដរ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការបង្កើតរោងចក្រផលិតអាវចាក់ របស់សាខាក្រុមហ៊ុន ជុងហ្វៃ នីតវៀរ អេហ្វជីវ៉ាយ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលាខេត្តកណ្តាល
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៤៦២ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៥

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រោមអត្តលេខ Co.៣៧៤៩KH/២០១៤ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៤ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ ដោយយោងសេចក្តីប្រកាសរបស់ក្រុមហ៊ុនដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : **ភីភី អ៊ីលីត រៀលធី លីមីធីត**
**PP ELITE REALTY LIMITED**
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ឆេកភី ច៉ាន ស៊ីខេ** ប្រធានក្រុមប្រឹក្សាភិបាល
លោក CHANG, TSAN-LIN អភិបាល

៣- ដើមទុនក្រុមហ៊ុន : ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្លូវវេងស្រេង ភូមិត្រពាំងថ្លូង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-សេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុ
-ទិញ លក់ និងវិនិយោគលើ ដី និងអចលនទ្រព្យ
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ
- ការជួសជុលសម្ភារៈ និងទំនិញគ្រប់ប្រភេទ
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-ផ្សាយពាណិជ្ជកម្ម បោះពុម្ព និងស្វែងរកទីផ្សារ
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-សេវាកម្រៃជើងសាលើការដឹកជញ្ជូន
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងថែរក្សាទំនិញ
-ទេសចរណ៍ : សណ្ឋាគារ រមណីយដ្ឋាន ភោជនីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម -រោងចក្រផលិតគ្រឿងបរិភោគ រោងចក្រផលិតឱសថ

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ ។

៦- ចិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ង៉ុក_ប្រជា

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងព័ត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- អគ្គនាយកដ្ឋានពន្ធដារ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ** ០៤៦៣ **ពណ.ចបព**

**ភ្នំពេញថ្ងៃទី** ០៩ **ខែ**មករា **ឆ្នាំ ២០**១៥

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រោមអត្តលេខ Co.៣៨៩៩E/២០១៤ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៤ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ ដោយយោងសេចក្តីប្រកាសរបស់ក្រុមហ៊ុនដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- | នាមករណ៍របស់ក្រុមហ៊ុន | : | **អ៊ីអាន ថេក (ខេមបូឌា)**<br>**IIAN TECH (CAMBODIA) Co., Ltd.** |
| | មានទ្រង់ទ្រាយជា | : | ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត |
| ២- | អភិបាលក្រុមហ៊ុន | : | លោក BAE SI HAN ប្រធានក្រុមប្រឹក្សាភិបាល<br>លោក LEE YOUNG CHOL អភិបាល |
| ៣- | ដើមទុនក្រុមហ៊ុន | : | ១២០.០០០.០០០ រៀល |
| ៤- | ទីស្នាក់ការក្រុមហ៊ុន | : | លេខ ១៦ ផ្លូវលេខ ៣ បុរីពិភពថ្មី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។ |
| ៥- | កម្មវត្ថុអាជីវកម្ម | : | -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណ ទំនិញគ្រប់ប្រភេទ<br>-នាំចូល និងចែកចាយឧបករណ៍បន្ទះសូឡា<br>-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសម្ភារៈទំនិញគ្រប់ប្រភេទ<br>-សេវាកម្មអចលនវត្ថុ និងសេវាកម្មវាយតម្លៃអចលនវត្ថុ<br>-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ<br>-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ<br>-បើកសាលារៀន<br>-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម<br>-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម<br>-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស<br>-សេវាផ្សាយពាណិជ្ជកម្ម<br>-សេវាផ្នែកព័ត៌មានវិទ្យា<br>-បោះពុម្ពផ្សាយ<br>-ផលិតខ្សែភាពយន្ត វីដេអូ CD<br>-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ<br>-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន |

-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់ -ស្ថាបត្យកម្ម រចនាប្លង់ ត្រួតពិនិត្យ និងសិក្សាគម្រោងប្លង់សំណង់គ្រប់ប្រភេទ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

រដ្ឋលេខាធិការ

ទិត្យ-ប្រាជ្ញ

**ចម្លងជូន**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- អគ្គនាយកដ្ឋានពន្ធដារ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ** ០៤៦៤ **ពណ.ចបព**

**ភ្នំពេញថ្ងៃទី** ១៥ **ខែ**មេសា **ឆ្នាំ** ២០១៥

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រោមអត្តលេខ Co.៣៩៣៤E/២០១៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ ដោយយោងសេចក្តីប្រកាសរបស់ក្រុមហ៊ុនដូចខាងក្រោមៈ

១- នាមករណ៍របស់ក្រុមហ៊ុន : **បេននី អ៊ិនវេសមិន (ខេមបូឌា)**
**BENNY'S INVESTMENT (CAMBODIA) Co., Ltd.**
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន :
លោក BUNYAMIN CIGDEMOGLU ប្រធានក្រុមប្រឹក្សាភិបាល
លោក SAKIP CATAL អភិបាល
លោក IBRAHIM CELIK អភិបាល
លោក FAIK FARIMAZ អភិបាល
លោក HAKAN OKTAY អភិបាល

៣- ដើមទុនក្រុមហ៊ុន : ២០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិ៤ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហាំណែ អាហាំណែ ទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សម្ភារៈបរិក្ខាពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសម្ភារៈទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្នែកព័ត៌មានវិទ្យា
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD/...

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់ -ស្ថាបត្យកម្ម រចនាប្លង់ ត្រួតពិនិត្យ និងសិក្សាគម្រោងប្លង់សំណង់គ្រប់ប្រភេទ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**ទ្រី-ប្រជា**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- អគ្គនាយកដ្ឋានពន្ធដារ
- សាលាខេត្តព្រះសីហនុ
  បន្ទីរពាណិជ្ជកម្មខេត្តព្រះសីហនុ " មុខការ "

ម.សរ - ឯកសារ - កាលប្បវត្តិ